ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

# ការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃទីភ្នាក់ងារ ធានាការវិនិយោគពហុភាគី

នស/រកម/០៦៩៩/០៤

# ព្រះរាជក្រម

## យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់-តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្រប នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ លើកទី១ នីតិកាល ទី១ ហើយដែលមានសេចក្តី ទាំងស្រុង ដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រម

# ឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិក

# នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា

# ចូលជាសមាជិក

# នៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី

**មាត្រា ១.–**

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការបង្កើតទីភ្នាក់ងារធានាការវិនិយោគពហុ-ភាគីដែលមានអត្ថបទភ្ជាប់មកជាមួយ និងយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ ។

**មាត្រា ២.–**

អនុម័តយល់ព្រមអោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទិញភាគហ៊ុនរបស់ទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ ជាទឹកប្រាក់ចំនួនប្រាំបួនរយសាមសិបពាន់ ( ៩៣០.០០០ ) អេស.ឌី.អ័រ ដោយអនុវត្តទៅតាមបែបបទ ដែលកំណត់ក្នុងអនុសញ្ញាស្តីពីការបង្កើតទីភ្នាក់ងារនេះ។

**មាត្រា ៣.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តនីតិវិធីទាំងឡាយដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជាជាសមាជិកនៃទីភ្នាក់ងារធានាការវិនិយោគពហុភាគីនេះ។

មាត្រា ៤.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ ៖ ១២៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ធាន់

# អនុសញ្ញា
# ស្ដីពី
# ការបង្កើត ទីភ្នាក់ងារធានា
# ការវិនិយោគពហុភាគី
# និង
# អត្ថាធិប្បាយ អំពីអនុសញ្ញានេះ

ដាក់ស្នើជូនចំពោះបណ្ដារដ្ឋាភិបាល

ដោយក្រុមប្រឹក្សាភិបាល នៃ

ធនាគារអន្តរជាតិ សំរាប់ការកសាង និងអភិវឌ្ឍន៍

ថ្ងៃទី ១១ ខែតុលា ឆ្នាំ ១៩៨៥

# អនុសញ្ញា ស្តីពីការបង្កើត ទីភ្នាក់ងារធានា ការវិនិយោគ ពហុភាគី

## បុព្វកថា

រដ្ឋដែលបានចុះកិច្ចសន្យា

ដោយបានគិតដល់សេចក្តីត្រូវការ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងដើម្បីជំរុញនូវការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍នេះ អំពីការវិនិយោគបរទេសនិយាយរួម និងដោយឡែកអំពីការវិនិយោគឯកជនបរទេស ។

ដោយទទួលស្គាល់ថា ចរន្តនៃការវិនិយោគបរទេសចំពោះប្រទេសអភិវឌ្ឍន៍ត្រូវបានសំរួលនិងលើកទឹកចិត្ត ដោយការបន្ធូរស្រាលទាក់ទងទៅនឹង ហានិភ័យមិនមែនពាណិជ្ជកម្ម (non-commercial rial) ។

ដោយចង់ធ្វើឱ្យប្រសើរឡើង នូវការហូរចូលនូវមូលធននិងបច្ចេកវិទ្យាសំរាប់គោលបំណងផលិតកម្ម ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ នៅក្រោមលក្ខខ័ណ្ឌ ដែលសមស្របទៅនឹងតំរូវការអភិវឌ្ឍ នយោបាយ និងគោលដៅ ឈរលើមូលដ្ឋានយុត្តិធម៌ និងនិយាមដែលមានស្ថេរភាព សំរាប់ប្រព្រឹត្តកម្មចំពោះការវិនិយោគបរទេស ។

ដោយជឿជាក់ថា ទីភ្នាក់ងារធានាការវិនិយោគពហុភាគី អាចបំពេញតួនាទីយ៉ាងសំខាន់ក្នុងការលើកទឹកចិត្តការវិនិយោគបរទេស ដោយបំពេញបន្ថែមនូវកម្មវិធីធានាចំពោះការវិនិយោគ ជាតិនិងតំបន់ និងអ្នកធានារ៉ាប់រងឯកជន នៃហានិភ័យមិនមែនពាណិជ្ជកម្ម ។

ដោយយល់ថា ទីភ្នាក់ងារបៀបនេះ អាចជួបនឹងការតាំងកិច្ចដោយមិនចាំបាច់ងាកអំពីបញ្ហាដើមទុន ចំពោះលទ្ធភាពពង្រីកបន្ថែម ហើយគោលដៅនេះអាចប្រើប្រាស់បានដោយ ការធ្វើឱ្យកាន់តែប្រសើរឡើងជានិច្ច ក្នុងលក្ខខ័ណ្ឌវិនិយោគ ។

បានយល់ព្រមដូចតទៅ ៖

### ជំពូក I

ការបង្កើត ស្ថានភាព (status). គោលបំណងនិងនិយមន័យ

មាត្រា ១ ការបង្កើតនិងស្ថានភាពនៃទីភ្នាក់ងារ

ក- ត្រូវបានបង្កើត ទីភ្នាក់ងារធានាការវិនិយោគពហុភាគី ( បន្តទៅទៀតហៅថា ទីភ្នាក់ងារ (Agency) ។

ខ- ទីភ្នាក់ងារនឹងមាននីតិបុគ្គលភាពពេញលេញ និងដោយឡែកមានសមត្ថភាព ក្នុងការ :

១- ធ្វើកិច្ចសន្យា

២- ទទួលនឹងមានចលនៈ និងអចលនៈទ្រព្យ និង

៣- ធ្វើបណ្ដឹងតាមផ្លូវច្បាប់ ។

មាត្រា ២ : ~~គោលដៅ និងគោលបំណង~~

គោលដៅនៃទីភ្នាក់ងារគឺលើកទឹកចិត្តដល់ការហូរចូលនូវការវិនិយោគសំរាប់គោលបំណងផលិតកម្ម ក្នុងចំណោមប្រទេសជាសមាជិក និងជាពិសេសចំពោះប្រទេសជាសមាជិកកំពុងអភិវឌ្ឍន៍ ក៏ដូចជាបន្ថែមសកម្មភាពរបស់ធនាគារអន្តរជាតិដើម្បីការកសាង និងកិច្ចអភិវឌ្ឍន៍ (បន្តទៅទៀតហៅថាធនាគារ ~~(Bank), សាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិ និង~~ស្ថាប័នហិរញ្ញវត្ថុអន្តជាតិ ដើម្បីអភិវឌ្ឍន៍ដទៃទៀត ។

ដើម្បីសំរេចនូវគោលដៅនេះ ទីភ្នាក់ងារនឹង :

ក- ផ្ដល់ការធានា គិតទាំងការរ៉ាប់រងរួមគ្នា (Coinsurance ) និងការរ៉ាប់រងជាថ្មី ( reinsurance ) ដល់ហានិភ័យមិនមែនពាណិជ្ជកម្ម ចំពោះការវិនិយោគនៅក្នុងប្រទេសជាសមាជិក ដែលហូរចូលពីប្រទេសជាសមាជិកដទៃទៀត ។

ខ- ធ្វើសកម្មភាពលើកទឹកចិត្តដ៏សមរម្យ ដើម្បីធ្វើឱ្យមាន ការហូរចូលការវិនិយោគទៅ និងក្នុងចំណោមប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ និង

គ- អនុវត្តអំណាចបន្ទាប់បន្សំ ( incidental powers ) ផ្សេងៗ តាមការចាំបាច់ ឬតាមបំណងដើម្បីធ្វើឱ្យចំរើនជឿនលឿនដល់គោលដៅនេះ ។

ទីភ្នាក់ត្រូវបានដឹកនាំនៅក្នុង ការសំរេចចិត្តទាំងអស់ដោយ ខ ( provisions ) ទាំងឡាយក្នុងមាត្រានេះ ។

មាត្រា ៣ : និយមន័យ

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

ក- "សមាជិក" ( Member ) មានន័យថា រដ្ឋមួយដែលអនុសញ្ញានេះបានចូលជាធរមាន ស្របតាមមាត្រា ៦១ ។

ខ- "ប្រទេសម្ចាស់ផ្ទះ" ឬ "រដ្ឋាភិបាលម្ចាស់ផ្ទះ" មានន័យថាសមាជិកមួយ រដ្ឋាភិបាល ឬអាជ្ញាធរសាធារណៈណាមួយ នៃសមាជិកមួយ ដែលនៅលើទឹកដីរបស់សមាជិកនោះ ដូចដែលបានកំណត់ក្នុងមាត្រា ៦៦ ត្រូវបានបោះទីតាំងការវិនិយោគមួយដែលបានទទួលការធានា ឬរ៉ាប់រងជាថ្មី ឬបានគិតទុកថាអាចទទួល ការធានា ឬរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ ។

ក- ប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ ( Developing member country ) មានន័យថា សមាជិកមួយដែលបានចុះបញ្ជីឈ្មោះក្នុងតារាងក (Schedule A) នៃការអនុសញ្ញានេះ ដែលតារាងនេះ អាចត្រូវ កែប្រែយូរៗម្តងដោយក្រុមប្រឹក្សាភិបាល ( Council of Governors ) យោងតាមមាត្រា ៣០ (បន្តទៅទៀត ហៅថាក្រុមប្រឹក្សា) ។

ឃ- ភាគច្រើនពិសេស ( Special majority ) មានន័យថា សំឡេងឆ្នោតសំរេចមួយ មិន តិចជាងពីរភាគបីនៃអំណាចឆ្នោតសរុប ដែលតំណាងឱ្យមិនតិចជាង ហាសិបប្រាំភាគរយនៃភាគហ៊ុន ដែលបានធ្វើបរិវិសកម្ម (subscribed shares)នៃ Capital Stock របស់ទីភ្នាក់ងារ ។

ង- រូបិយវត្ថុដែលអាចប្រើប្រាស់បានដោយសេរី ( freely usable Currency ), មានន័យ ថា (១) រូបិយវត្ថុណាមួយដែលត្រូវជ្រើសរើសយកដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ( International Monetary fund)យូរៗម្តង (២) រូបិយវត្ថុដែលមានតម្លៃនិងប្រសិទ្ធិភាពប្រើប្រាស់ដោយសេរីផ្សេង ទៀតដែលគណៈកម្មការនាយក ( Board of Directors ) ដែលយោងក្នុងមាត្រា ៣០ (បន្តទៀតហៅ ថាគណៈកម្មការ ) បានជ្រើសយកក្នុងគោលបំណងសំរាប់អនុសញ្ញានេះ បន្ទាប់ពីការពិគ្រោះយោបល់ ជាមួយនឹងមូលនិធិរូបិយវត្ថុអន្តរជាតិ និងដែលបានទទួលការយល់ព្រមពីប្រទេសម្ចាស់រូបិយវត្ថុនោះ ។

## ជំពូក II
## សមាជិកភាព និងដើមទុន
## (Memberslip and Capital)

មាត្រា ៤ : សមាជិកភាព

ក- សមាជិកភាពនៅក្នុងទីភ្នាក់ងារ នឹងត្រូវបើកចំហចំពោះគ្រប់សមាជិករបស់ធនាគារ និង ចំពោះប្រទេសស្វីស ។

ខ- សមាជិកដំបូង គឺជាបណ្តារដ្ឋដែលបានចុះបញ្ជីក្នុងតារាង ក ក្នុងឯកសារនេះ និងក្លាយ ជាភាគីនៃអនុសញ្ញានេះ នៅថ្ងៃ ឬមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៨៧ ។

មាត្រា ៥ : ដើមទុន

ក- ភាគហ៊ុនសរុប ( Capital Stock ) ដែលត្រូវបានអនុញ្ញាតិរបស់ទីភ្នាក់ងារមានចំនួនមួយ កោដិ Special Drawing Rights ( S.D.R 1.000.000.000 ) ។ ភាគហ៊ុនជាដើមទុន នឹងត្រូវបែង ចែកជា 100.000 ហ៊ុន ដែលហ៊ុននីមួយៗមានតម្លៃស្មើនឹង ១០.០០០ S.D.R ដែលជាតម្លៃសំរាប់ ប្រើប្រាស់បានក្នុងការ ជាវហ៊ុន របស់សមាជិក ។ រាល់កាតព្វកិច្ចបង់ប្រាក់របស់សមាជិក ចំពោះ ភាគហ៊ុនដើមទុន ត្រូវបានព្រមព្រៀងនៅលើមូលដ្ឋាននៃតម្លៃមធ្យមរបស់ S.D.R ធៀបទៅនឹងដុល្លា

សហរដ្ឋ សំរាប់រយៈពេលពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨១ ដល់ ១៩៨៥ ដែលតម្លៃនេះស្មើនឹង ១.០៨២ ដុល្លាសហរដ្ឋ ក្នុង ១ S.D.R ។

ខ- ភាគហ៊ុននៃមូលធននឹងបង្កើន ក្នុងការទទួលសមាជិកថ្មី នៅពេលដែល ភាគហ៊ុនដែលបានអនុញ្ញាតិនៅពេលនោះ មានចំនួនមិនគ្រប់គ្រាន់សំរាប់ផ្តល់ឱ្យសមាជិក ជាវ អនុលោមតាមមាត្រា ៦ ។

គ- ដោយភាគច្រើនពិសេស ក្រុមប្រឹក្សាអាចបង្កើនភាគហ៊ុនសរុបរបស់ទីភ្នាក់ងារ នៅពេលណាក៏បាន ។

មាត្រា ៦ : ការជាវហ៊ុន (Subscription of Shares)

សមាជិកដំបូងនិមួយៗរបស់ទីភ្នាក់ងារ នឹងជាវស្មើនឹងចំនួនហ៊ុន នៃភាគហ៊ុនសរុប ដែលបានចុះចល់មុខនឹងឈ្មោះខ្លួននៅក្នុងតារាង គ នៃឯកសារនេះ ។ សមាជិកនិមួយៗផ្សេងទៀត នឹងជាវចំនួនហ៊ុននៃ~~ភាគហ៊ុនសរុបតាមចំណែកនិងលក្ខខ័ណ្ឌ~~ ដែលអាចកំណត់ដោយក្រុមប្រឹក្សា~~ប៉ុន្តែទោះជាយ៉ាងណា~~ តម្លៃចុះដំបូងមិនត្រូវតិចជាងតម្លៃប្រកាស។ គ្មានសមាជិកណាមួយ នឹងជាវតិចជាង ហាសិបហ៊ុនទេ ។ ក្រុមប្រឹក្សាអាចនឹងកំណត់ច្បាប់ដែលតាមច្បាប់នេះ សមាជិកអាចជាវហ៊ុនបន្ថែមពីភាគហ៊ុនសរុបដែលបានអនុញ្ញាត្តិ ។

មាត្រា ៧ : ការបែងចែក និងការសុំឱ្យបង់តម្លៃហ៊ុនដែលបានជាវ ការជាវដំបូងរបស់សមាជិកនីមួយៗនឹងត្រូវបង់ប្រាក់ដូចតទៅ :

១- ក្នុងរយៈពេល កៅសិប ថ្ងៃ ចាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន ចំពោះសមាជិកនោះដប់ភាគរយនៃតម្លៃហ៊ុននីមួយៗត្រូវបង់ភ្លាមៗ ដូចដែលបានចែងក្នុងផ្នែក គ នៃមាត្រា ៨ ហើយនឹងដប់ភាគរយបន្ថែមទៀត ក្នុងរូបភាពមិនអាចជំនួសបាន គ្មានការប្រាក់ដោយមានលិខិតកិច្ចសន្យា ឬក៏ការសន្យាប្រហាក់ប្រហែលគ្នា ដែលត្រូវបង់ចំពោះការសំរេចចិត្តរបស់គណៈកម្មការ នៅពេលមានលិខិតទាមទារបំណុលរបស់ទីភ្នាក់ងារ ។

២- ប្រាក់ដែលនៅសល់គឺជាកម្មវត្ថុ នៃការសុំឱ្យបង់ដោយទីភ្នាក់ងារនៅពេលដែលត្រូវការ ។

មាត្រា ៨ : ការបង់ប្រាក់ ភាគហ៊ុនដែលបានជាវ

ក- ការបង់ប្រាក់នៃការជាវ ត្រូវប្រើប្រាស់រូបិយវត្ថុដែលអាចប្រើបានដោយសេរី លើកលែងតែការបង់ប្រាក់របស់ប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ ដែលអាចប្រើប្រាស់រូបិយវត្ថុផ្ទាល់របស់គេបាន រហូតដល់ម្ភៃប្រាំភាគរយ នៃចំណែកដែលត្រូវបង់ភ្លាមៗ ចំពោះការជាវរបស់គេដែលអាចបង់តាមមាត្រា ៧ (១)។

ខ- ការសុំឱ្យបង់ប្រាក់នៅលើចំណែកណាមួយ នៃការជាវដែលមិនទាន់បានបង់ប្រាក់ នឹងត្រូវស្មើគ្នា ចំពោះហ៊ុនទាំងអស់ ។

ក- ប្រសិនបើចំនួនដែលទទួលដោយទីភ្នាក់ងារ ក្នុងការសុំឱ្យបង់លើកទីមួយ មិនគ្រប់គ្រាន់សំរាប់លើកទាំងឱ្យបង់ដែលតម្រូវសុំឱ្យបង់បន្ថែមទៀត ទីភ្នាក់ងារអាចធ្វើសេចក្តីស្នើសុំឱ្យបង់ជាបន្តបន្ទាប់ទៀត លើការធានាដែលមិនទាន់បានបង់ រហូតដល់ចំនួនដែលបានទទួលទាំងអស់មានចំនួនគ្រប់គ្រាន់ ។

ឃ- ការទទួលខុសត្រូវលើភាគហ៊ុនត្រូវបានកំរិតត្រឹម ចំណែកដែលមិនទាន់បានបង់ នៃតម្លៃដែលបានដាក់ចុះ ។

មាត្រា ៩ : ការវាយតម្លៃរូបិយវត្ថុ

ក- នៅពេលដែលមានការចាំបាច់ ក្នុងគោលបំណងនៃអនុសញ្ញានេះ ដើម្បីកំណត់តម្លៃនៃរូបិយវត្ថុមួយ ធៀបទៅនឹងរូបិយវត្ថុមួយទៀត ជាការសមហេតុផល ដែលតម្លៃនេះនឹងត្រូវកំណត់ដោយទីភ្នាក់ងារ បន្ទាប់ពីការពិគ្រោះយោបល់ជាមួយនឹង មូលនិធិរូបិយវត្ថុអន្តរជាតិ ។

មាត្រា ១០ : ការប្រគល់ប្រាក់មកវិញ ( Refunds )

ក- ទីភ្នាក់ងារនឹងប្រគល់ប្រាក់ដែលសមាជិកបានបង់តាមការសុំឱ្យបង់លើដើមទុន ដែលបានធានាត្រឡប់មកវិញ យ៉ាងឆាប់រហ័សតាមដែលអាចធ្វើបាន ប្រសិនបើ និងរហូតដល់ :

១- ការសុំឱ្យបង់ប្រាក់ត្រូវបានធ្វើដើម្បីសងសំណង បណ្តាលមកពីកិច្ចសន្យាធានា ឬការរ៉ាប់រងជាថ្មី ហើយបន្ទាប់មកទីភ្នាក់ងារបានទូទាត់ការបង់នេះទាំងស្រុង ឬក៏ជាផ្នែក ដោយរូបិយវត្ថុដែលអាចប្រើបានដោយសេរី ឬ

២- ការសុំឱ្យបង់នេះធ្វើឡើងដោយសារកំហុសក្នុងការបង់ប្រាក់របស់សមាជិក ហើយក្រោយមកសមាជិកនោះបានអនុវត្តល្អតាមកិច្ចសន្យាទាំងស្រុង ឬក៏ជាផ្នែក ឬ

៣- ក្រុមប្រឹក្សាបានសំរេចដោយភាគច្រើន ពិសេសថា ស្ថានភាពហិរញ្ញវត្ថុរបស់ទីភ្នាក់ងារអាចអនុញ្ញាតិឱ្យ បញ្ចេញទឹកប្រាក់មួយចំនួនទាំងអស់ ឬក៏មួយចំណែក ពីប្រាក់ចំណូលរបស់ទីភ្នាក់ងារ។

៤- ការប្រគល់ប្រាក់ឱ្យសមាជិកវិញ ដែលធ្វើឱ្យមានឡើងតាមមាត្រានេះ ត្រូវប្រើរូបិយវត្ថុដែលអាចប្រើបានដោយសេរី នៅតាមសមាមាត្រនៃការបង់ប្រាក់របស់សមាជិក ចំពោះទឹកប្រាក់បង់សរុបអនុលោមទៅតាមការសុំឱ្យបង់ប្រាក់ ដែលធ្វើមុនមានការប្រគល់ប្រាក់ឱ្យវិញនេះ ។

ក- តម្លៃស្មើគ្នានឹងចំនួនដែលបានប្រគល់ឱ្យសមាជិកវិញតាមមាត្រានេះ នឹងក្លាយទៅជាការសន្យាដើមទុនដែលអាចសុំឱ្យបង់បានពីសមាជិកតាមមាត្រា ៧ (២) ។

# ជំពូក III

# ប្រតិបត្តិការ

# (Operations )

មាត្រា ១១ : គ្រោះថ្នាក់ដែលត្រូវបានការពារ

ក- កម្មវត្ថុនៃ ខ នៅក្នុងផ្នែក (ខ) និង (គ) ខាងក្រោម ទីភ្នាក់ងារ អាចធានាចំពោះការវិនិយោគដ៏សមប្រកប ទល់នឹងការបាត់បង់បណ្តាលមកពីគ្រោះថ្នាក់មួយ ឬច្រើនប្រភេទខាងក្រោមនេះ :

១- ការផ្ទេររូបិយវត្ថុ ( Currency Transfer )

ការណែនាំដែលអាចពន្យល់ពីមូលហេតុដល់រដ្ឋាភិបាលម្ចាស់ផ្ទះ អំពីការរឹតត្បិតលើការផ្ទេររូបិយវត្ថុរបស់គេចេញក្រៅ ពីប្រទេសម្ចាស់ផ្ទះទៅជារូបិយវត្ថុដែលអាចប្រើបានដោយសេរី ឬរូបិយវត្ថុមួយផ្សេងទៀត ដែលអាចទទួលយកបានដោយអ្នកដែលបានទទួលការធានា ដោយគិតទាំងការអាក់ខានរបស់រដ្ឋាភិបាលម្ចាស់ផ្ទះក្នុងការធ្វើសកម្មភាព នៅក្នុងរយៈពេលសមស្របមួយ ចំពោះលិខិតស្នើសុំដោយអ្នកដែលបានទទួលការធានា ចំពោះការផ្ទេរនេះ ។

២- អស្សាមិករណ៍ (ការរឹបអូសទ្រព្យសម្បត្តិតាមផ្លូវច្បាប់) និងវិធានការប្រហាក់ប្រហែល ( Expropriation and similar Mesures )

សកម្មភាពនីតិបញ្ញត្តិ ឬរដ្ឋបាលណាមួយ ឬការលុបបំបាត់ដែលអាចពន្យល់ពីមូលហេតុ ដល់រដ្ឋាភិបាលម្ចាស់ផ្ទះ ដែលមានអនុភាពដកហូតពីអ្នកដែលបានទទួលការធានា នូវកម្មសិទ្ធិ ឬការត្រួតត្រា ឬផលចំណេញដ៏គ្រាស់ក្រែលអំពី ការវិនិយោគរបស់គេ ដោយលើកលែងចេញនូវវិធានការមិនប្រកាន់បក្សពួកនៃការអនុវត្តន៍ទូទៅ ដែលជាធម្មការរដ្ឋាភិបាលប្រកាន់យកក្នុងគោលបំណងតែសំរួល សកម្មភាពសេដ្ឋកិច្ចនៅក្នុងទឹកដីរបស់ខ្លួន ។

៣- ការប្រព្រឹត្តិខុសនឹងកិច្ចសន្យា

ការបោះបង់ចោល ឬ ការប្រព្រឹត្តិខុសនឹងកិច្ចសន្យាជាមួយអ្នកដែលបានទទួលការធានារបស់រដ្ឋាភិបាលម្ចាស់ផ្ទះ នៅពេលដែល (ក) អ្នកដែលបានទទួលការធានាមិនបានរកជំនួយតាមផ្លូវច្បាប់ ឬការកាត់សេចក្តីដោយតុលាការ ដើម្បីកំណត់ពីជំទាស់ទៅនឹងការបាត់បង់ ឬធ្វើខុសកិច្ចសន្យា ឬ(ខ) ការសំរេចដោយវេទិការខាងលើ មិនបានប្រគល់ឱ្យក្នុងរយៈពេលសមស្រប ដូចដែលនឹងកំណត់ នៅក្នុងកិច្ចសន្យាបានដោយអនុលោមតាមបទបញ្ជារបស់ទីភ្នាក់ងារ ឬ(គ) សេចក្តីសំរេចនេះមិនអាចត្រូវបានបង្ខំឱ្យប្រតិបត្តិនឹង ។

៤- សង្គ្រាម និងចលាចលស៊ីវិល

សកម្មភាពយោធា ឬចលាចលស៊ីវិលណាមួយ នៅក្នុងដែនដីប្រទេសម្ចាស់ផ្ទះណាមួយ ដែលអនុសញ្ញានេះអាចត្រូវបានអនុវត្តដូចមានចែងក្នុងមាត្រា ៦៦ ។

ខ- ឈរលើការស្នើសុំរួមរបស់វិនិយោគិន និងប្រទេសម្ចាស់ផ្ទះ គណៈកម្មការ ដោយភាគច្រើនពិសេសអាចយល់ព្រមពង្រីកកិច្ចការពារក្រោមមាត្រានេះ ចំពោះគ្រោះថ្នាក់មិនមែនពាណិជ្ជកម្មជាក់លាក់ក្រៅពីអ្វីដែលបានយោងក្នុងផ្នែក (ក) ខាងលើប៉ុន្តែគ្មានករណី ចំពោះការចុះតម្លៃ និងបញ្ចុះតម្លៃរូបិយវត្ថុទេ ។

គ- ការបាត់បង់បណ្ដាលមកពីករណីខាងក្រោមនេះ មិនត្រូវបានទូទាត់ទេ :

១- សកម្មភាពណាមួយរបស់រដ្ឋាភិបាលម្ចាស់ផ្ទះ ឬការកេ្ខចដែលអ្នកមានការធានាបានយល់ព្រម ឬដែលខ្លួនជាអ្នកទទួលខុសត្រូវ និង

២- សកម្មភាពណាមួយរបស់រដ្ឋាភិបាលម្ចាស់ផ្ទះ ឬការកេ្ខច ឬព្រឹត្តិការណ៍ផ្សេងទៀតដែលកើតឡើងមុនពេលធ្វើកិច្ចសន្យាធានា ចប់ ។

មាត្រា ១២ : ការវិនិយោគដ៏សមប្រកប ( Eligible Investments )

ក- ការវិនិយោគដ៏សមប្រកប នឹងគិតបញ្ចូលពីផលប្រយោជន៍ស្មើភាពគ្នា ដែលគិតបញ្ចូលទាំងប្រាក់ចងការរយៈពេលមធ្យម ឬរយៈពេលវែង ដែលបានធ្វើ ឬបានធានាដោយអ្នកដែលកាន់កាប់ភាគស៊ើនៅក្នុងសហគ្រាសដែលពាក់ព័ន្ធ ហើយដែលការវិនិយោគផ្ទាល់ របៀបនេះ អាចត្រូវបានកំណត់ដោយគណៈកម្មការ ។

ខ- ដោយភាគច្រើនពិសេស គណៈកម្មការអាចពង្រីកភាពដែលអាចជ្រើសយកបាន ( Eligibility ) ចំពោះការវិនិយោគដែលមានរូបភាពរយៈពេលមធ្យម ឬវែង លើកលែងតែប្រាក់ចងការក្រៅពីបាននិយាយក្នុងផ្នែក (ក) ខាងលើអាចត្រូវបានជ្រើសយកលុះត្រាតែការវិនិយោគនេះ មានទាក់ទងទៅនឹងការវិនិយោគជាក់លាក់មួយ ដែលការពារ ឬត្រូវបានការពារដោយទីភ្នាក់ងារ ។

គ- ការធានានឹងត្រូវកំណត់ត្រឹមការវិនិយោគ ដែលបានដំណើរការចាប់ផ្ដើមជាបន្តពីការចុះបញ្ជីពាក្យស្នើសុំការធានា ដោយទីភ្នាក់ងារ ។ ការវិនិយោគរបៀបនេះអាចរាប់បញ្ចូល :

១- ការផ្ទេររូបិយវត្ថុបរទេសណាមួយ ដែលធ្វើឡើងដើម្បីឱ្យទំនើប ពង្រីក ឬអភិវឌ្ឍ ការវិនិយោគដែលមានស្រាប់ និង

២- ការប្រើប្រាស់នូវប្រាក់ចំណូលពីការវិនិយោគដែលមានស្រាប់ ដែលបើមិនដូច្នេះទេ អាចផ្ទេរចេញពីប្រទេសម្ចាស់ផ្ទះបាន ។

ឃ- ក្នុងការធានាការវិនិយោគមួយ ទីភ្នាក់ងារបានពេញចិត្តចំពោះខ្លួនឯង ដោយ :

១- ភាពរឹងមាំផ្នែកសេដ្ឋកិច្ច របស់ការវិនិយោគ និងការចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសម្ចាស់ផ្ទះ ។

២- ការសម្រប រវាងការវិនិយោគជាមួយច្បាប់ និងបទបញ្ញារបស់ប្រទេសម្ចាស់ផ្ទះ ។

៣- ស្មេរភាពនៃការវិនិយោគ ជាមួយនឹងគោលដៅអភិវឌ្ឍន៍ និងអទិភាពរបស់ប្រទេសម្ចាស់ផ្ទះ និង

៤ - ស្ថានភាពវិនិយោគ នៅក្នុងប្រទេសម្ចាស់ផ្ទះ ដែលគិតបញ្ចូលទាំងភាពដែលអាចរកបាន នូវធម្មើយុត្តិធម៌ និងសមធម៌ និងការពារតាមផ្លូវច្បាប់សំរាប់ការវិនិយោគ ។

មាត្រា ១៣ : វិនិយោគិនដែលសមប្រកប

ក- ធម្មជាតិបុគ្គល និងនីតិបុគ្គលណាមួយអាចត្រូវបានជ្រើសយកដើម្បីទទួលការធានាពីទីភ្នាក់ងារ ត្រូវបានកំណត់ថា :

១- ធម្មជាតិបុគ្គលនោះ គឺជាជនជាតិរបស់ប្រទេសសមាជិកមួយ ក្រៅពីប្រទេសម្ចាស់ផ្ទះ ។

២- នីតិបុគ្គលនោះ បានចូលរួមជាមួយ និងមានទីតាំងអាជីវកម្មជាមូលដ្ឋាន នៅក្នុងប្រទេសសមាជិក ឬក៏ភាគច្រើននៃដើមទុនរបស់គេ ជាកម្មសិទ្ធិរបស់សមាជិកមួយ ឬច្រើន ឬជាតិច្រើននោះ ត្រូវបានថែងថា សមាជិកនោះមិនមែនជាប្រទេសម្ចាស់ផ្ទះ ក្នុងករណីណាមួយខាងលើ និង

៣- នីតិបុគ្គលនោះ ទោះបីមាន ឬក៏មិនមានកម្មសិទ្ធិឯកជនបានប្រតិបត្តិលើមូលដ្ឋានអាជីវកម្ម

ខ- ក្នុងករណីដែលវិនិយោគិនមានសញ្ជាតិលើសពីមួយ ដើម្បីគោលបំណងនៃផ្នែក (ក) ខាងលើ សញ្ជាតិនៃប្រទេសសមាជិក លើសលុប សញ្ជាតិនៃប្រទេសមិនមែនសមាជិក ហើយសញ្ជាតិនៃប្រទេសម្ចាស់ផ្ទះ លើសលុបលើសញ្ជាតិនៃប្រទេសសមាជិកណាមួយដទៃទៀត ។

គ- ឈរលើពាក្យស្នើរ របស់វិនិយោគិន និងប្រទេសម្ចាស់ផ្ទះ ដោយភាគច្រើនពិសេសគណៈកម្មការអាចពង្រីក ភាពអាចជ្រើសយកបានចំពោះធម្មជាតិបុគ្គល ដែលមានសញ្ជាតិ នៃប្រទេសម្ចាស់ផ្ទះ ឬក៏នីតិបុគ្គលដែលបានរួមប្រតិបត្តិការនៅក្នុងប្រទេសម្ចាស់ផ្ទះ ឬភាគច្រើននៃដើមទុនរបស់គេកាន់កាប់ដោយជាតិគេបានកំណត់ថា ទ្រព្យសម្បត្តិដែលបានវិនិយោគ បានផ្ទេរចេញពីប្រទេសម្ចាស់ផ្ទះ ។

មាត្រា ១៤ : ប្រទេសម្ចាស់ផ្ទះដ៏សមប្រកប

ការវិនិយោគដែលនឹងត្រូវបានធានា ក្រោមជំពូកនេះ លុះត្រាតែការវិនិយោគនេះបានធ្វើនៅក្នុងទឹកដីនៃប្រទេសសមាជិកកំពុងអភិវឌ្ឍមួយ ។

មាត្រា ១៥ : ការយល់ព្រមពីប្រទេសម្ចាស់ផ្ទះ

ទីភ្នាក់ងារមិនត្រូវសំរេចចុះកិច្ចសន្យាធានាណាមួយ មុនពេលដែលរដ្ឋាភិបាលម្ចាស់ផ្ទះ បានយល់ព្រមចំពោះការចេញ ការធានាដោយទីភ្នាក់ងារ ទល់នឹងគ្រោះថ្នាក់ដែលត្រូវបានការពារ ។

មាត្រា ១៦ : រយៈពេល និងលក្ខខ័ណ្ឌ

រយៈពេល និងលក្ខខ័ណ្ឌនៃកិច្ចសន្យាធានានីមួយៗ ត្រូវបានកំណត់ដោយទីភ្នាក់ងារ ដែលកម្មវត្ថុនៃវិន័យនិងបទបញ្ញាដែលគណៈកម្មការនឹងដាក់ចេញបានថែងថា ទីភ្នាក់ងារមិនត្រូវទូទាត់សង

ការខាតបង់ទាំងស្រុងរបស់វិនិយោគដែលបានធានា ។ កិច្ចសន្យាធានាត្រូវបានយល់ព្រមដោយប្រធាន ( President ) ក្រោមការណែនាំរបស់គណៈកម្មការ ។

មាត្រា ១៧ : ការបង់ប្រាក់ចំពោះការទាមទារសំណង

ប្រធាន ក្រោមការណែនាំរបស់គណៈកម្មការ នឹងសំរេចចិត្តចំពោះការបង់ប្រាក់ទាមទារសំណងចំពោះអ្នកដែលបានទទួលការធានាស្របទៅតាមកិច្ចសន្យាធានា និងបណ្ណភិបាលដែលគណៈកម្មការអាចទទួលបាន ។ កិច្ចសន្យាធានានឹងទាមទារឱ្យអ្នកដែលទទួលការធានា រកបង្វែរមូលធន ដែលអាចសមរម្យតាមកាលៈទេសៈ ដែលកំណត់ថា បង្វែរនោះមានតម្លៃចំពោះគេទៅតាមច្បាប់របស់ប្រទេសម្ចាស់ផ្ទះ ។ កិច្ចសន្យានេះអាចត្រូវការរយៈពេលសមស្រប រវាងព្រឹត្តិការណ៍កើតឡើងបណ្តាលឱ្យមានការទាមទារសំណង នឹងការបង់ប្រាក់ទាមទារសំណង ។

មាត្រា ១៨ : ( Subrogation ) (ការចាត់តាំងតំណាង )

ក- ដោយរបើការបង់ប្រាក់ ឬការយល់ព្រមបង់ប្រាក់ទូទាត់សំណងចំពោះអ្នកដែលទទួលការធានា ទីភ្នាក់ងារនឹងត្រូវចាត់ជាតំណាង ចំពោះសិទ្ធិ ឬការទាមទារដែលទាក់ទងទៅនឹងការវិនិយោគដែលបានធានា ដូចដែលអ្នកទទួលការធានាអាចមានទល់នឹងប្រទេសម្ចាស់ផ្ទះ និងឥណយិកដទៃទៀត ។ កិច្ចសន្យាធានានឹងកំណត់ពេលនិងលក្ខខណ្ឌនៃការចាត់តាំងតំណាងនោះ ។

ខ- សិទ្ធិរបស់ទីភ្នាក់ងារស្របទៅតាមផ្នែក (ក) ខាងលើត្រូវបានទទួលស្គាល់ដោយសមាជិកទាំងអស់ ។

គ- ចំនួនទៃរូបិយវត្ថុរបស់ប្រទេសម្ចាស់ផ្ទះ ដែលរកបានដោយទីភ្នាក់ងារដែលជាអ្នកតំណាងស្របតាមផ្នែក (ក) ខាងលើ អាចត្រូវបានយល់ព្រមក្នុងគោលបំណងប្រើប្រាស់ ការផ្លាស់ប្តូរការប្រព្រឹត្តិដោយប្រទេសម្ចាស់ផ្ទះ ដែលប្រាក់សងនេះគួរតែត្រូវបានប្រគល់ជលដៃ អ្នកដែលបានទទួលការធានា ។ ក្នុងករណីខ្លះ ទឹកប្រាក់នេះអាចត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារសំរាប់បង់ថ្លៃការចំណាយរដ្ឋាភិបាល និងតម្លៃផ្សេងទៀត ។ ទីភ្នាក់ងារក៏នឹងស្វែងរកការសំរុះសំរួលជាមួយប្រទេសម្ចាស់ផ្ទះចំពោះការប្រើប្រាស់ ផ្សេងៗទៀតនៃរូបិយវត្ថុនេះ នៅពេលដែលរូបិយវត្ថុនេះ មិនអាចប្រើប្រាស់បានដោយសេរី ។

មាត្រា ១៩ : ទំនាក់ទំនង នឹងអង្គភាព ( Entity ) ជាតិនិងតំបន់

ទីភ្នាក់ងារនឹងសហការ ហើយនឹងស្វែងរកបន្ថែមប្រតិបត្តិការជាមួយអង្គភាពជាតិរបស់សមាជិក និងអង្គភាពតំបន់ដែលភាគច្រើនទៃដើមទុនរបស់គេ កាន់កាប់ដោយសមាជិក ដែលធ្វើមានសកម្មភាពប្រហាក់ប្រហែលគ្នានឹងទីភ្នាក់ងារ ក្នុងគោលបំណងបង្កើនជាអតិបរិមា ទាំងប្រសិទ្ធិភាពសេវាកម្មរបស់គេ ទាំងការរួមវិភាគទានក្នុងការបង្កើនការហូរចូល ការវិនិយោគបរទេស ។ ត្រង់ចំណុចនេះទីភ្នាក់ងារ

អាចយោងទៅរកការរៀបចំជាមួយបណ្ដាអង្គភាពនេះ លំអិតអំពីការសហការ គិតបញ្ចូលជាពិសេសទាំងប្រភេទនៃការរ៉ាប់រងជាថ្មី និងការរ៉ាប់រងរួមគ្នា ។

មាត្រា ២០ : ការរ៉ាប់រងជាថ្មី ( Reinsurance ) នៃអង្គភាពជាតិ និងតំបន់

ក- ទីភ្នាក់ងារអាចចេញការរ៉ាប់រងជាថ្មីចំពោះការវិនិយោគជាក់លាក់ ទល់នឹងការបាត់បង់ដែលបណ្ដាលឡើងពីគ្រោះថ្នាក់មិនមែនពាណិជ្ជកម្មមួយ ឬច្រើន ដែលបានធានាដោយសមាជិក ឬទីភ្នាក់ងារ ( Agency ) ឬដោយទីភ្នាក់ងារធានាការវិនិយោគតំបន់ ដែលភាគច្រើននៃដើមទុន ជាកម្មសិទ្ធិរបស់សមាជិក ។ ដោយភាគច្រើនពិសេសគណៈកម្មការ នឹងកំណត់យ៉ាងម្ដងអំពីចំនួនអតិបរិមានៃលទ្ធភាពបំណុល ( Contingent liability ) ដែលអាចទទួលបន្ទុកដោយទីភ្នាក់ងារចំពោះកិច្ចសន្យារ៉ាប់រងជាថ្មី ។ ចំពោះការវិនិយោគជាក់លាក់ដែលបានបំពេញសព្វគ្រប់ច្រើនជាងដប់ពីរខែ មុនការទទួលទទួលពាក្យស្នើសុំសំរាប់ការរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ ចំនួនអតិបរិមាអាចកំណត់ជាដំបូងស្មើនឹងដប់ភាគរយនៃលទ្ធភាពបំណុលរួមរបស់ទីភ្នាក់ងារ តាមជំពូកនេះ ។ លក្ខខ័ណ្ឌនៃការចូលរួមដែលបញ្ជាក់នៅក្នុងមាត្រា ១១ ដល់ ១៤ នឹងអនុវត្តចំពោះប្រតិបត្តិការរ៉ាប់រងជាថ្មី លើកលែងតែវិនិយោគដែលមានការរ៉ាប់រងជាថ្មី មិនត្រូវការបំពេញបន្ត នូវពាក្យស្នើសុំសំរាប់ការរ៉ាប់រងជាថ្មី ។

ក- សិទ្ធិ និងការតព្វកិច្ចទៅវិញទៅមក របស់ទីភ្នាក់ងារនិងសមាជិកដែលបានទទួលការរ៉ាប់រងជាថ្មី ឬទីភ្នាក់ងារ ( Agency ) នឹងត្រូវបានចែងនៅក្នុងកិច្ចសន្យារ៉ាប់រងជាថ្មី ដែលកម្មវត្ថុនៃច្បាប់នឹងវិន័យត្រូវបានដាក់ចេញដោយគណៈកម្មការ ។ គណៈកម្មការនឹងសំរេចយល់ព្រមកិច្ចសន្យាសំរាប់ការរ៉ាប់រងជាងនីមួយៗដែលការពារ ការវិនិយោគមួយដែលបានធ្វើមុន នឹងទទួលពាក្យស្នើសុំសំរាប់ការរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ ក្នុងគោលបំណងបន្ថយគ្រោះថ្នាក់ជាអតិបរិមា ដែលធានាថាទីភ្នាក់ងារទទួលប្រាក់ធានាភ័យប្រហាក់ប្រហែលនឹងគ្រោះថ្នាក់របស់គេ និងដែលធានាថា អង្គភាពដែលបានទទួលការរ៉ាប់រងជាថ្មី បានប្រព្រឹត្តិសមរម្យល្មមក្នុងការលើកទឹកចិត្តការវិនិយោគថ្មី នៅក្នុងប្រទេសសមាជិកអភិវឌ្ឍន៍ ។

ក- តាមលទ្ធភាពដែលអាចធ្វើបាន ទីភ្នាក់ងារ ( Agency ) នឹងធានាថាខ្លួន ឬអង្គភាពដែលបានទទួលការរ៉ាប់រងជាថ្មី នឹងមានសិទ្ធិក្នុងការចាត់តាំងតំណាង និងការកាត់ក្ដីដោយតុលាការ ដូចគ្នានឹងអ្វីដែលទីភ្នាក់ងារអាចនឹងទទួលបាន ប្រសិនបើគេជាអ្នកធានាលើកដំបូង ។ រយៈពេលនឹងលក្ខខ័ណ្ឌនៃការធានាជាថ្មី នឹងត្រូវការនូវបង្វែករដ្ឋបាលស្របទៅតាមមាត្រា ១៧ មុនពេលបង់ប្រាក់ដល់ទីភ្នាក់ងារ ។ ការចាត់តាំងតំណាងនឹងមានប្រសិទ្ធិភាពចំពោះប្រទេសម្ចាស់ផ្ទះដែលជាប់ទាក់ទងលុះត្រាតែបន្ទាប់ពីបានទទួលការយល់ព្រមរ៉ាប់រងជាថ្មីពីទីភ្នាក់ងារ ។ ទីភ្នាក់ងារនឹងបញ្ចូលទៅក្នុងកិច្ចសន្យាជាថ្មី នូវ (ខ) កំណត់ដែលទាមទារ អ្នកដែលបានទទួលការរ៉ាប់រងជាថ្មី ត្រូវបន្តការព្យាយាម

ហួតដល់ពេលកំណត់នូវសិទ្ធិ ឬការទាមទារដែលទាក់ទងទៅនឹងការវិនិយោគដែលបានទទួលភិបាលជាថ្មី ។

មាត្រា ២១ : សហប្រតិបត្តិការជាមួយអ្នកភិបាលឯកជន និងជាមួយអ្នកភិបាលជាថ្មី

ក- ទីភ្នាក់ងារអាចចូលរួមរៀបចំ ជាមួយអ្នកភិបាលឯកជន នៅក្នុងប្រទេសសមាជិក ដើម្បីបង្កើនប្រតិបត្តិការផ្ទាល់ខ្លួនរបស់គេ និងដើម្បីលើកទឹកចិត្តអ្នកធានាឱ្យផ្តល់ការការពារដល់គ្រោះថ្នាក់មិនមែនពាណិជ្ជកម្ម នៅក្នុងប្រទេសសមាជិកអភិវឌ្ឍ ក្នុងលក្ខខ័ណ្ឌដូចគ្នានឹងអ្វីដែលទីភ្នាក់ងារបានអនុវត្ត ។ ការរៀបចំនេះអាចបញ្ចូល (ខ) កំណត់នៃការភិបាលជាថ្មីដោយទីភ្នាក់ងារ នៅក្រោមលក្ខខ័ណ្ឌនិងដំណើរការ ដែលបានបញ្ជាក់នៅក្នុងមាត្រា ២០ ។

ខ- ទីភ្នាក់ងារអាចភិបាលជាថ្មី ជាមួយអង្គភាពភិបាលជាថ្មីសមស្របណាមួយ ទាំងស្រុង ឬក៏ជាផ្នែក នូវការធានាណាមួយ ឬការធានាទាំងឡាយណាដែលចេញដោយទីភ្នាក់ងារ ។

គ- ទីភ្នាក់ងារនឹងស្វែងរកដោយឡែក ដើម្បីធានាការវិនិយោគទាំងឡាយដែលសំណងប្រៀបធៀប ក្នុងរយៈពេលសមស្របណាមួយ មិនអាចធ្វើបានដោយអ្នកភិបាលឯកជន និងអ្នកភិបាលជាថ្មី ។

មាត្រា ២២ : ដែនកំណត់នៃការធានា

ក- លើកលែងតែត្រូវបានកំណត់ផ្សេងពីនេះ ដោយក្រុមប្រឹក្សា ដោយភាពច្រើនពិសេស ចំនួនសរុបរួមនៃលទ្ធភាពបំណុល ដែលទទួលបន្ទុកដោយទីភ្នាក់ងារក្នុងជំពូកនេះ នឹងមិនត្រូវលើសពីមួយរយហាសិបភាគរយនៃចំនួនដើមទុនដែលមិនបាន បញ្ចុះតម្លៃរបស់ទីភ្នាក់ងារ និងប្រាក់បំរុងបូកនឹងចំណែកនៃការទូទាត់សងការធានាជាថ្មីនេះ ដែលអាចកំណត់ដោយគណៈកម្មការ ។ យូរៗម្តងគណៈកម្មការនឹងពិនិត្យឡើងវិញនូវរូបភាពនៃគ្រោះថ្នាក់ នៅក្នុងបញ្ជីលេខរៀង ( Portfolio) នៃការវិនិយោគរបស់ទីភ្នាក់ងារ នៅក្នុងពន្លឺនៃការពិសោធន៍ ជាមួយនឹងការទាមទារសំណង កំរិតនៃការបែងចែកប្រភេទគ្រោះថ្នាក់ ការទូទាត់ការភិបាលជាថ្មី និងកត្តាដែលកើតឡើងផ្សេងទៀត ក្នុងគោលបំណងរកឱ្យឃើញថាការប្រែប្រួលចំនួនសរុបអតិបរិមានៃលទ្ធភាពបំណុល គួរត្រូវបានបញ្ជាដោយក្រុមប្រឹក្សា ។ ចំនួនអតិបរិមាដែលកំណត់ដោយក្រុមប្រឹក្សា ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវលើសពីប្រាំដងនៃចំនួនដើមទុនដែលមិនបានបញ្ចុះតម្លៃរបស់ទីភ្នាក់ងារ ប្រាក់បំរុង និងចំណែកនៃការទូទាត់សងការភិបាលជាថ្មី ដែលត្រូវបានវិនិច្ឆ័យដោយសមស្រប ។

ខ- ដោយមិនធ្វើឱ្យខូចខាត ចំពោះដែនកំណត់ទូទៅនៃការធានា ដែលយោងទៅផ្នែក (ក) ខាងលើ គណៈកម្មការអាចកំណត់ :

១- ចំនួនបូករួមអតិបរិមានៃលទ្ធភាពបំណុល ដែលអាចទទួលបន្ទុកដោយទីភ្នាក់ងារ នៅក្នុងជំពូកនេះ ចំពោះការធានាទាំងអស់ ដែលបានផ្តល់ឱ្យវិនិយោគិននៃសមាជិកនីមួយៗ ។ ក្នុងការកំណត់ចំនួនអតិបរិមានេះ គណៈកម្មការនឹងផ្តល់អ្វីដែលសមស្របទៅនឹងភាគហ៊ុននៃសមាជិកនោះ នៅក្នុងដើម

ទុនរបស់ទីភ្នាក់ងារហើយនឹង សេចក្តីត្រូវការអនុវត្តការកំណត់ព្រំដែនឱ្យកាន់តែទូលាយ ចំពោះការវិនិយោគ ដែលមានប្រភពនៅក្នុងប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ និង ។

២- ចំនួនបូកសរុបអតិបរិមា នៃលទ្ធភាពបំណុលដែលអាចទទួលបន្ទុកដោយទីភ្នាក់ងារ ចំពោះកត្តារំលងចែកគ្រោះថ្នាក់ ដែលនៅតែរោងផ្ទាល់ខ្លួន ប្រទេសម្ចាស់ផ្ទះផ្ទាល់ និងប្រភេទនៃការវិនិយោគ ឬគ្រោះថ្នាក់ ។

មាត្រា ២៣ : ការលើកទឹកចិត្តវិនិយោគ

ក- ទីភ្នាក់ងារ នឹងធ្វើការស្រាវជ្រាវ បានរាប់រងសកម្មភាពដើម្បីលើកទឹកចិត្ត ដល់ការហូរចូលវិនិយោគ និងផ្សព្វផ្សាយពត៌មានអំពីឱកាសល្អសំរាប់វិនិយោគ នៅក្នុងប្រទេសសមាជិកកំពុងអភិវឌ្ឍក្នុងគោលបំណងបញ្ជាក់ពីបរិស្ថានសំរាប់ការហូរចូល ការវិនិយោគបរទេសចំពោះប្រទេសនេះ ។ អាស្រ័យទៅតាមសំណូមពររបស់សមាជិកមួយ ទីភ្នាក់ងារអាចផ្តល់នូវដំបូន្មាន និងជំនួយបច្ចេកទេសដើម្បីបញ្ជាក់លក្ខខ័ណ្ឌវិនិយោគ នៅក្នុងទឹកដីសមាជិកនោះ ។ ដើម្បីធ្វើសកម្មភាពនេះ ទីភ្នាក់ងារនឹង:

១- ត្រូវបានដឹកនាំដោយលើកការព្រមព្រៀងវិនិយោគក្នុងចំណោមប្រទេសសមាជិក ។

២- ខិតខំលុបបំបាត់ឧបសគ្គ ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ចំពោះការហូរចូលវិនិយោគទៅក្នុងប្រទេសសមាជិកកំពុងអភិវឌ្ឍ និង ។

៣- ទំនាក់ទំនងជាមួយទីភ្នាក់ងារ ( Agencies ) ដទៃទៀត ដែលទាក់ទងទៅនឹងការលើកទឹកចិត្តដល់វិនិយោគបរទេស និងដោយឡែកជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។

ខ- ទីភ្នាក់ងារ ក៏នឹង :

១- លើកទឹកចិត្តដល់ដំណោះស្រាយជំលោះប្រកបដោយមេត្រីភាពរវាង វិនិយោគិន និងប្រទេសម្ចាស់ផ្ទះ ។

២- ខំប្រឹងខ្នះខ្នែងបង្កើយកិច្ចព្រមព្រៀងជាមួយប្រទេសសមាជិក កំពុងអភិវឌ្ឍ និងដោយឡែកចំពោះប្រទេសម្ចាស់ផ្ទះ ដែលនឹងធានាថាទីភ្នាក់ងារបានប្រព្រឹត្តិយ៉ាងហោចណាស់ ក៏អាចធ្វើទៅបានដូចដែលបានយល់ព្រមដោយសមាជិកដែលពាក់ព័ន្ធ សំរាប់ទីភ្នាក់ងារធានាវិនិយោគដែលអនុគ្រោះបំផុត ហើយកិច្ចព្រមព្រៀងនេះត្រូវបានយល់ព្រមដោយភាគច្រើនពិសេសរបស់គណៈកម្មការ និង .

៣- លើកទឹកចិត្ត និងសំរួលដល់ការបង្កើយកិច្ចព្រមព្រៀង លើការលើកទឹកចិត្ត និងការការពារវិនិយោគក្នុងចំណោមសមាជិក ។

មាត្រា ២៤ : ការធានាចំពោះ វិនិយោគដែលមានការធានា ( Sponsored Investments ) ជាបន្ថែមទៅនឹងប្រតិបត្តិការធានា ដែលធ្វើដោយទីភ្នាក់ងារនៅក្នុងជំពូកនេះ ទីភ្នាក់ងារអាចធានាចំពោះការវិនិយោគដែលស្ថិតនៅក្រោមការធានា ដែលការព្រមព្រៀងនៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ ។

# ជំពូក IV
# សំវិធានហិរញ្ញវត្ថុ
## (Financial Provisions )

មាត្រា ២៥ : ការគ្រប់គ្រងហិរញ្ញវត្ថុ ( Financial Management )

ទីភ្នាក់ងារនឹងធ្វើសកម្មភាព អាស្រ័យដោយអាជីវកម្មរឹងមាំ និងការគ្រប់គ្រងហិរញ្ញវត្ថុប្រុងប្រយ័ត្ន អនុវត្តដើម្បីរក្សានូវភាពប៉ិនប្រសប់នៅក្នុងគ្រប់កាលៈទេសៈ ប្រឈមមុខនឹងការតឹងកិច្ចហិរញ្ញវត្ថុ ។

មាត្រា ២៦ : ប្រាក់កំរៃ និងប្រាក់ឈ្នួល ( Primiums and Fees )

ទីភ្នាក់ងារ គួរធ្វើនិទស្សន៍ និងពិនិត្យឡើងវិញក្នុងចន្លោះពេលទៀងទាត់អំពីកំរិតនៃប្រាក់កំរៃបន្ថែម ប្រាក់ឈ្នួល និងប្រាក់បន្ទុកផ្សេងៗទៀត ប្រសិនបើមាន ដែលអាចអនុវត្តបានចំពោះប្រភេទគ្រោះថ្នាក់នីមួយៗ ។

មាត្រា ២៧ : ការបែងចែកប្រាក់ចំណូលសុទ្ធសាធ ( Allocation of Net Income )

ក- ដោយមិនធ្វើឱ្យខូចខាត ចំពោះ (ខ) ដែលបានចែងក្នុងផ្នែក (ក-៣) នៅក្នុងមាត្រា ១០ ទីភ្នាក់ងារនឹងបែងចែកទុកដាក់ដោយឡែក នូវប្រាក់ចំណូលសុទ្ធសំរាប់បំរុង រហូតដល់ប្រាក់បំរុងនេះកើនដល់ប្រាំដង នៃដើមទុនដែលបានជារបស់ទីភ្នាក់ងារ ។

ខ- បន្ទាប់ពីប្រាក់បំរុងរបស់ទីភ្នាក់ងារ បានកើនដល់កំរិតដែលបានបញ្ញត្តិនៅក្នុងផ្នែក (ក) ខាងលើ ក្រុមប្រឹក្សានឹងសំរេចថា តើក្នុងកំរិតណាដែលប្រាក់ចំណូលសុទ្ធសាធរបស់ទីភ្នាក់ងារ នឹងត្រូវទុកដាក់សំរាប់បំរុង ត្រូវបែងចែក ចំពោះសមាជិកនៃទីភ្នាក់ងារ ឬត្រូវប្រើប្រាស់ផ្សេងៗទៀត ។ ការបែងចែកណាមួយនៃប្រាក់ចំណូលសុទ្ធសាធ ចំពោះសមាជិកទីភ្នាក់ងារ នឹងត្រូវធ្វើតាមសមាមាត្រនៃភាគហ៊ុនរបស់សមាជិកនីមួយៗ ក្នុងមូលធននៃទីភ្នាក់ងារដោយអនុលោមជាមួយនឹងការសំរេចចិត្តរបស់ក្រុមប្រឹក្សា ដែលសំដែងដោយភាគច្រើនពិសេស ។

មាត្រា ២៨ : ថវិកា ( Budget )

ប្រធាន ( Prisedents ) នឹងរៀបចំថវិកាចំណូល និងចំណាយប្រចាំឆ្នាំរបស់ទីភ្នាក់ងារ ដែលត្រូវសំរេចយល់ព្រមដោយគណៈកម្មការ ។

មាត្រា ២៩ : គណនី ( Accounte )

ទីភ្នាក់ងារ នឹងបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំមួយ ដែលមានតុល្យការ នៃគណនីរបស់ខ្លួន និងគណនីរបស់ ( Sponsoship Toust Fund * ) ដែលយោងទៅឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះដែល ( * មូលនិធិទុកចិត្តលើការធានា)

ឯកសារនេះត្រូវចុះហត្ថលេខាដោយអ្នកជំនាញបញ្ជីឯករាជ្យ ។ ទីភ្នាក់ងារ នឹងផ្សព្វផ្សាយទៅសមាជិកទៅក្នុងចន្លោះពេលសមស្របមួយ នូវតុល្យការសរុបនៃស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន និងតុល្យការចំណេញខាត ដែលបង្ហាញពីលទ្ធផលនៃប្រតិបត្តិការរបស់ខ្លួន ។

## ជំពូក V

## ការរៀបចំ និងការគ្រប់គ្រង

## ( Organisation and Management )

មាត្រា ៣០ : រចនាសម្ព័ន្ធនៃទីភ្នាក់ងារ

~~ទីភ្នាក់ងារ នឹងមានក្រុមប្រឹក្សាភិបាលមួយ គណៈកម្មការនាយកមួយ ប្រធានមួយ ( Prisedent) និង~~បុគ្គលិកដើម្បីបំពេញកិច្ចការ តាមដែលទីភ្នាក់ងារអាចកំណត់ឱ្យ ។

មាត្រា ៣១ : ក្រុមប្រឹក្សា

ក- អំណាចទាំងអស់របស់ទីភ្នាក់ងារ នឹងត្រូវប្រគល់ឱ្យក្រុមប្រឹក្សាលើកលែងតែអំណាចណាតាមរយៈពេលនៃអនុសញ្ញានេះ ដែលត្រូវបានប្រគល់ឱ្យទៅអង្គការណាមួយផ្សេងទៀតរបស់ទីភ្នាក់ងារ ។ ក្រុមប្រឹក្សាអាចផ្ទេរទៅឱ្យគណៈកម្មការអនុវត្តនូវអំណាចណាមួយរបស់ខ្លួន លើកលែងតែអំណាច :

១- ទទួលសមាជិកថ្មី និងកំណត់លក្ខខ័ណ្ឌក្នុងការទទួល

២- បញ្ឈប់សមាជិកមួយជាបណ្ដោះអាសន្ន

៣- សំរេចលើការបង្កើន ឬបន្ថយដើមទុន

៤- បង្កើនដែនកំណត់ នៃចំនួនសរុបរួមនៃលទ្ធភាពបំណុលតាមផ្នែក (ក) នៃមាត្រា ២២ ។

៥- ជ្រើសតាំងសមាជិកមួយថាជាប្រទេសសមាជិកកំពុងអភិវឌ្ឍតាមផ្នែក (ក) នៃមាត្រា ៣

៦- ធ្វើចំណាត់ថ្នាក់សមាជិកថ្មីមួយ ឲ្យចូលទៅក្នុងប្រភេទទីមួយ ឬប្រភេទទីពីរ ដោយការបោះឆ្នោត តាមផ្នែក (ក) នៃមាត្រា ៣៩ ឬធ្វើចំណាត់ថ្នាក់ជាថ្មីចំពោះសមាជិកចាស់ក្នុងគោលបំណងដូចគ្នា ។

៧- កំណត់ប្រាក់ទូទាត់សំរាប់បណ្ឌានាយក និងអ្នកជំនួស

៨- បញ្ឈប់ប្រតិបត្តិការ និងរំលាយទីភ្នាក់ងារ

៩- បែងចែកទ្រព្យសម្បត្តិ ចំពោះសមាជិក នៅពេលរំលាយទីភ្នាក់ងារ

១០-ធ្វើវិសោធនកម្មអនុសញ្ញានេះ ឧបសម្ព័ន្ធ និងតារាង ( Schedules )

ខ- ក្រុមប្រឹក្សា នឹងមានសមាសភាព អភិបាលម្នាក់ និងអ្នកជំនួសម្នាក់ ដែលចាត់តាំងឡើងដោយសមាជិកនីមួយៗ ។ អ្នកជំនួសមិនអាចបោះឆ្នោតបានទេ លើកលែងតែអភិបាលអវត្តមាន ។

ក្រុមប្រឹក្សា នឹងជ្រើសរើសទេសាភិបាលម្នាក់ ក្នុងចំណោមបណ្តាទេសាភិបាលឱ្យធ្វើជាប្រធានក្រុមប្រឹក្សា ( Chairman ) ។

គ- ក្រុមប្រឹក្សា នឹងធ្វើការប្រជុំប្រចាំឆ្នាំ និងការប្រជុំផ្សេងទៀត ដែលអាចកំណត់ដោយក្រុមប្រឹក្សា ឬដែលកោះប្រជុំដោយគណៈកម្មការ ។ គណៈកម្មការនឹងកោះប្រជុំក្រុមប្រឹក្សានៅពេលដែលមានសំណូមពរពីសមាជិកចំនួនប្រាំ ឬដោយសមាជិកដែលមាន អំណាចបោះឆ្នោតចំនួនម្ភៃប្រាំភាគរយ ។

មាត្រា ៣២ : គណៈកម្មការ

ក- គណៈកម្មការនឹងត្រូវទទួលខុសត្រូវ សំរាប់ប្រតិបត្តិការទូទៅរបស់ទីភ្នាក់ងារ ហើយដើម្បីបំពេញនូវការទទួលខុសត្រូវនេះ ត្រូវធ្វើសកម្មភាពដែលទាមទារ ឬអនុញ្ញាតិដោយអនុសញ្ញានេះ ។

ខ- គណៈកម្មការត្រូវមាននាយក មិនតិចជាងដប់ពីនាក់ ។ ចំនួននាយកអាចកែសំរួលដោយក្រុមប្រឹក្សា ដោយគិតទៅតាមការប្រែប្រួលសមាជិកភាព។ នាយកនីមួយៗអាចចាត់តាំងអ្នកជំនួសម្នាក់ ដែលមានអំណាចពេញលេញ ក្នុងការធ្វើសកម្មភាពជំនួសបាន ក្នុងករណីដែលនាយកអវត្តមាន ឬមិនអាចធ្វើសកម្មភាពបាន។ ប្រធានធនាគារ (President of the Bank) នឹងក្លាយជាប្រធានដោយសារតំណែង (exofficio Chairman ) នៃគណៈកម្មការ ប៉ុន្តែមិនអាចចូលរួមបោះឆ្នោត លើកលែងតែការបោះឆ្នោតសំរេច ក្នុងករណីដែលមានសំលេងស្មើគ្នា ។

គ- ក្រុមប្រឹក្សានឹងកំណត់រយៈពេលកាន់តំណែងរបស់នាយក។ គណៈកម្មការទីមួយនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សា ក្នុងឱកាសប្រជុំសម្ពោធដំបូង ។

ឃ- គណៈកម្មការនឹងជួបប្រជុំ តាមការកោះអញ្ជើញរបស់ប្រធានក្រុមប្រឹក្សា ( Chairman ) ដែលធ្វើសកម្មភាពតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមសំណូមពររបស់នាយកបីនាក់។

ង- រហូតដល់ពេលដែលក្រុមប្រឹក្សាអាចសំរេចថា ទីភ្នាក់ងារនឹងមានគណៈកម្មការជាប់លាប់ ដែលធ្វើការនៅសម័យប្រជុំបន្ត បណ្តានាយកនិងអ្នកជំនួសនឹងទទួលការទូទាត់ត្រឹមតែតម្លៃនៃការដែលចូលរួមក្នុងការប្រជុំនៃគណៈកម្មការ និងការបំពេញកិច្ចការផ្លូវការក្នុងនាមទីភ្នាក់ងារ ។ នៅពេលដែលបានបង្កើតគណៈកម្មការនៅក្នុងសម័យប្រជុំបន្ត នាយកនិងអ្នកជំនួស នឹងត្រូវបានទទួលប្រាក់ឈ្នួលដែលអាចកំណត់ដោយក្រុមប្រឹក្សា ។

មាត្រា ៣៣ : ប្រធានគណៈកម្មការ និងបុគ្គលិក (President and staff)

ក- ក្រោមការត្រួតពិនិត្យទូទៅរបស់គណៈកម្មការ ប្រធាននឹងដឹកនាំកិច្ចការសាមញ្ញរបស់ទីភ្នាក់ងារ ។ ប្រធានគណៈកម្មការនឹងទទួលខុសត្រូវចំពោះការរៀបចំតែងតាំង និងបណ្តេញបុគ្គលិក ។

ខ- ប្រធាន (President )នឹងត្រូវបានតែងតាំងដោយគណៈកម្មការដោយការចង្អុលឈ្មោះពីប្រធានក្រុមប្រឹក្សា ( Chairman ) ។ ក្រុមប្រឹក្សានឹងកំណត់ប្រាក់បៀវត្ស និងរយៈពេលកិច្ចសន្យាការងាររបស់ប្រធានគណៈកម្មការ ។

គ- នៅក្នុងការបំពេញការងារការិយាល័យ ប្រធានគណៈកម្មការនិងបុគ្គលិក បំពេញកិច្ចការទាំងស្រុងសំរាប់ទីភ្នាក់ងារ ហើយមិនសំរាប់អាជ្ញាធរណាផ្សេងទៀតទេ។ សមាជិកនិមួយៗរបស់ទីភ្នាក់ងារនឹងគោរពចរិកអន្តរជាតិនៃកិច្ចការនេះ ហើយនឹងទប់រាល់ការប៉ុនប៉ងបញ្ចេញឥទ្ធិពលលើប្រធាន និងបុគ្គលិកនៅពេលបំពេញកិច្ចការរបស់ខ្លួន ។

ឃ- ក្នុងការតែងតាំងបុគ្គលិក ដែលគោលដៅគឺសារៈសំខាន់ជំឧត្តមក្នុងការធានាប្រសិទ្ធិភាពកំរិតខ្ពស់បំផុត និងសមត្ថភាពបច្ចេកទេស ប្រធានគណៈកម្មការនឹងត្រូវគិតដល់សារៈសំខាន់ នៃការជ្រើសរើសបុគ្គលិកនៅលើមូលដ្ឋានភូមិសាស្ត្រទូលំទូលាយ តាមដែលអាចធ្វើបាន ។

ង- ប្រធានគណៈកម្មការនិងបុគ្គលិក នឹងត្រូវរក្សាគ្រប់ពេលវេលានូវការសំងាត់នៃព័ត៌មានដែលបានទទួលក្នុងប្រតិបត្តិការរបស់ទីភ្នាក់ងារ ។

មាត្រា ៣៤ : សកម្មភាពនយោបាយដែលត្រូវហាមឃាត់

ទីភ្នាក់ងារ ប្រធានគណៈកម្មការនិងបុគ្គលិក មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការនយោបាយរបស់សមាជិកណាមួយទេ ។ ដោយមិនធ្វើការវិនិច្ឆ័យជាមុន ចំពោះសិទ្ធិរបស់ទីភ្នាក់ ដែលត្រូវគិតគូរគ្រប់កាលៈទេសៈ ជុំវិញការវិនិយោគមួយគេមិនត្រូវទទួលឥទ្ធិពល ក្នុងការសំរេចចិត្តដោយចរិកនយោបាយរបស់សមាជិក ឬសមាជិកដែលពាក់ព័ន្ធ ។ ការពិចារណាដែលនាំទៅដល់ការសំរេចចិត្ត ត្រូវសង្កត់ទៅលើភាពមិនលំអៀង ដើម្បីសំរេចតាម តាមគោលបំណងដែលចែងក្នុងមាត្រា ២ ។

មាត្រា ៣៥ : ទំនាក់ទំនង ជាមួយអង្គការអន្តរជាតិ

នៅក្នុងអណត្តិនៃអនុសញ្ញានេះ ទីភ្នាក់ងារ នឹងរួមសហប្រតិបត្តិការជាមួយសហប្រជាជាតិ និងជាមួយអង្គការអន្តររដ្ឋាភិបាលផ្សេងទៀត ដែលមានការទទួលខុសត្រូវជំនាញ ទាក់ទងនឹងវិស័យនេះរាប់បញ្ចូលដោយឡែកនូវធនាគារ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។

មាត្រា ៣៦ : ទីតាំងនៃការិយាល័យធំ ( Principal office )

ក- ការិយាល័យធំនៃទីភ្នាក់ងារ នឹងត្រូវតាំងនេះរដ្ឋធានីវ៉ាស៊ីនតោន (Washington D.C) លើកលែងតែដោយភាគច្រើនពិសេសក្រុមប្រឹក្សាសំរេចតាំង នៅទីកន្លែងដ៏ទៃទៀត ។

ខ- ទីភ្នាក់ងារអាចបង្កើតការិយាល័យដ៏ទៃទៀត ដែលអាចចាំបាច់សំរាប់ការងារ ។

មាត្រា ៣៧ : កន្លែងទុកដាក់ទ្រព្យសម្បត្តិ (Depositories for Assets)

សមាជិកនិមួយៗត្រូវជ្រើសរើសធនាគារកណ្តាលរបស់ខ្លួន ជាទីកន្លែងទុកដាក់ ដែលទីភ្នាក់ងារ

អាចរក្សាទុក រូបិយវត្ថុរបស់សមាជិក និងទ្រព្យសម្បត្តិដទៃទៀតរបស់ទីភ្នាក់ងារ ឬបើមិនមានធនាគារកណ្តាលបែបនេះ សមាជិកត្រូវជ្រើសរើសស្ថាប័នផ្សេងទៀតសំរាប់គោលបំណងនេះ ដែលអាចទទួលយកបានដោយទីភ្នាក់ងារ ។

មាត្រា ៣៨ : បណ្តាញទំនាក់ទំនង ( Channel of Communication ).

ក- សមាជិកនីមួយៗ នឹងជ្រើសតាំងអាជ្ញាធរសមស្របមួយ ដែលទីភ្នាក់ងារអាចទាក់ទងជាមួយបានចំពោះព្រឹត្តិការដែលកើតឡើងក្រោមអនុសញ្ញានេះ ។ ទីភ្នាក់ងារអាចទុកចិត្តចំពោះ ការថ្លែងរបស់អាជ្ញាធរនេះ ថាជាការថ្លែងរបស់សមាជិក ។ តាមការស្នើសុំរបស់សមាជិក ទីភ្នាក់ងារនឹងពិគ្រោះជាមួយសមាជិកនោះ ចំពោះបញ្ហាដែលត្រូវដោះស្រាយ ក្នុងមាត្រា ១៩ ដល់ ២១ និងដែលទាក់ទងជាមួយបណ្តាអង្គភាព ឬអ្នករ៉ាប់រងរបស់សមាជិកនោះ ។

ខ- នៅពេលដែលត្រូវការ ការយល់ព្រមរបស់សមាជិកណាមួយ មុនពេលដែលសកម្មភាពអាចត្រូវបានធ្វើដោយទីភ្នាក់ងារ ការយល់ព្រមនោះនឹងត្រូវចាត់ទុកថាបានការ លើកលែងតែសមាជិកបង្ហាញការជំទាស់ក្នុងចន្លោះពេលសមស្របមួយដែលទីភ្នាក់ងារអាចកំណត់ ។

## ជំពូក VI

## ការបោះឆ្នោត ការកែសំរួលបរិវិសកម្ម និងការតំណាង

## (Voting Adjustments of Subscriptions and Representations)

មាត្រា ៣៩ : ការបោះឆ្នោត និងការកែសំរួលបរិវិសកម្ម

ក- ដើម្បីឱ្យការរៀបចំបោះឆ្នោត ឆ្លុះបញ្ចាំងពីផលប្រយោជន៍ស្មើគ្នាក្នុងទីភ្នាក់ងារ នៃប្រភេទរដ្ឋទាំងពីរដែលចុះក្នុងតារាង ក នៃអនុសញ្ញានេះ ហើយនិងសារៈសំខាន់នៃការចូលរួមហិរញ្ញវត្ថុរបស់សមាជិកនីមួយៗ សមាជិកនីមួយៗនឹងមានសំឡេងសមាជិកភាព ( Membership Vote ) ចំនួន ១៧៧ សំឡេងបន្ថែម សំឡេងបរិវិសកម្មមួយ ( Subscription Vote ) សំរាប់ភាគហ៊ុននីមួយៗ ដែលសមាជិកមាន ។

ខ- ប្រសិនបើពេលណាមួយ ក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ផលបូករួមនៃសំឡេងសមាជិកភាព និងសំឡេងបរិវិសកម្មរបស់សមាជិក ដែលស្ថិតនៅក្នុងរដ្ឋប្រភេទទាំងពីរយ៉ាងចុះក្នុងតារាង ក នៃអនុសញ្ញានេះ តិចជាងសែសិបភាគរយនៃអំណាចបោះឆ្នោតទាំងអស់ បណ្តាសមាជិកនៃប្រភេទនោះ នឹងបានទទួលសំឡេងបោះឆ្នោតបន្ថែមតាមការចាំបាច់ ដើម្បីឱ្យអំណាច

បោះឆ្នោតអតិប្រភេទនោះស្មើគ្នានឹងភាគរយ នៃអំណាចបោះឆ្នោតទាំងអស់ ។ សំឡេងបន្ថែមនេះ នឹងត្រូវបែងចែកក្នុងចំណោមសមាជិកនៃប្រភេទនោះ តាមសមាមាត្រដែលសំឡេងបរិសកម្មនៃភាគហ៊ុន ( Bears ) និមួយៗ ចំពោះសំឡេងបរិសកម្មរួមនៃប្រភេទនេះ ។ សំឡេងបន្ថែមនេះ នឹងនៅជាកម្មវត្ថុសំរាប់ការ កែសំរួលជាស្វ័យប្រវត្ត ដើម្បីធ្វើឱ្យប្រាកដថា ភាគរយនោះត្រូវបានរក្សាឱ្យនៅដដែល ហើយនឹងត្រូវលុបចោលទៅវិញ នៅចុងបញ្ចប់នៃរយៈពេលបីឆ្នាំ ដែលបាននិយាយពីខាងលើ ។

ក- នៅឆ្នាំទីបី ចាប់ពីអនុសញ្ញានេះចូលជាធរមាន ក្រុមប្រឹក្សាត្រួតពិនិត្យឡើងវិញ នូវការបែងចែកភាគហ៊ុន ហើយត្រូវបានកំរែតំរង់ការសំរេចចិត្តរបស់ខ្លួន ដោយគោលការណ៍ខាងក្រោមនេះ ៖

១- សំឡេងឆ្នោតនៃសមាជិកត្រូវឆ្លុះបញ្ចាំងពីបរិសកម្ម ដើមទុន នៃទីភ្នាក់ងារ និងសំឡេងសមាជិកភាព ដែលបាននិយាយនៅក្នុងផ្នែក ខ នៃមាត្រានេះ ។

២- ភាគហ៊ុនដែលបានបែងចែក ចំពោះប្រទេសដែលនឹងមិនបានចុះហត្ថលេខា លើអនុសញ្ញា នឹងអាចមានតម្លៃសំរាប់ធ្វើការបែងចែកសាជាថ្មី ចំពោះសមាជិកនោះ និងដោយរបៀបនេះ ដើម្បីផ្តល់លទ្ធភាពដល់យុត្តភាព នៃការបោះឆ្នោតរវាងប្រភេទដែលបាននិយាយពីខាងលើ និង ។

៣- ក្រុមប្រឹក្សានឹងចាត់វិធានការដែលនឹងសំរួលដល់លទ្ធភាពរបស់សមាជិក ដើម្បីជាភាគហ៊ុនដែលបានបែងចែកសំរាប់គេ ។

ឃ- នៅក្នុងរយៈពេលបីឆ្នាំដែលបានកំណត់ខាងលើ ក្នុងផ្នែក ( ខ ) នៃមាត្រានេះ រាល់ការសំរេចចិត្តរបស់ក្រុមប្រឹក្សា និងគណៈកម្មការត្រូវធ្វើដោយភាគច្រើនពិសេស លើកលែងតែការសំរេចចិត្តដែលត្រូវការភាគច្រើនខ្ពស់ជាង នៅក្នុងអនុសញ្ញានេះ ត្រូវសុំដោយភាគច្រើនជាងនេះ ។

ង- ក្នុងករណីដែលដើមទុនរបស់ភ្នាក់ងារត្រូវបង្កើតតាមផ្នែក ( គ ) នៃមាត្រា ៥ សមាជិកនីមួយៗ ត្រូវបានអនុញ្ញាតឱ្យជាវតាមសមាមាត្រនៃការបង្កើន សមមូលទៅនឹងសមាមាត្រ ដែលភាគហ៊ុនដែលបានជាវចំពោះដើមទុនទាំងអស់របស់ទីភ្នាក់ងារ ក៏ប៉ុន្តែគ្មានសមាជិកណាមួយត្រូវបានបង្ខំឱ្យជាវចំណែកណាមួយនៃដើមទុន ដែលត្រូវបង្កើននោះទេ ។

ច- ក្រុមប្រឹក្សានឹងចាត់ចេញវិធានការ ក្នុងការធ្វើឱ្យមានការជាវបន្ថែមតាមផ្នែក (ង) នៃមាត្រានេះ ។ វិធានការនេះ នឹងបញ្ញត្តិរយៈពេលសមស្របមួយ សំរាប់ការចុះចូលដោយសមាជិកដើម្បីស្នើសុំធ្វើបរិសកម្មនេះ ។

មាត្រា ៤០ ៖ ការបោះឆ្នោតនៅក្នុងក្រុមប្រឹក្សា

ក- អភិបាលនីមួយៗត្រូវបានទទួលអំណាចបោះឆ្នោតរបស់សមាជិក ដែលខ្លួនតំណាងឱ្យ ។ លើកលែងតែត្រូវបានបញ្ជាក់ផ្សេងដោយផ្នែកទៀតនៅក្នុងអនុសញ្ញានេះ សេចក្តីសំរេចរបស់ក្រុមប្រឹក្សានឹងយកតាមភាគច្រើននៃសំឡេងបោះឆ្នោត ។

ខ- កូរ៉ុំ ( Quorum ) សំរាប់ការប្រជុំណាមួយ នៃក្រុមប្រឹក្សាត្រូវបានបង្កើតដោយភាគច្រើននៃអភិបាល ដែលមានចំនួនមិនតិចជាងពីភាគបីនៃអំណាចបោះឆ្នោតសរុប ។

គ- តាមបទបញ្ញត្តិក្រុមប្រឹក្សាអាចបង្កើតវិធីចាត់ការ ដែលគណៈកម្មការអាចសុំសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សា លើបញ្ហាពិសេសដោយឡែកដោយមិនចាំបាច់កោះប្រជុំក្រុមប្រឹក្សា នៅពេលដែលគេយល់ថា សកម្មភាពរបៀបនេះ មានផលប្រយោជន៍ល្អបំផុតសំរាប់ទីភ្នាក់ងារ ។

មាត្រា ៤១ : ការបោះឆ្នោតជ្រើសរើស ( Election of Directors )

ក- នាយកនឹងត្រូវបោះឆ្នោតជ្រើសរើសស្របតាមតារាង ១

ខ- បណ្តានាយកនឹងនៅបន្តក្នុងតំណែង រហូតដល់អ្នកបន្តតំណែងត្រូវបានជ្រើសរើស ។ ប្រសិនបើតំណែងរបស់នាយកម្នាក់នៅទំនេរលើសពីកៅសិបថ្ងៃ មុនពេលបញ្ចប់អាណត្តិ នាយកម្នាក់ទៀតនឹងត្រូវបានជ្រើសរើសសំរាប់រយៈពេលអាណត្តិ ដែលនៅសល់ ដោយបណ្តាអភិបាលដែលបានបោះឆ្នោតជ្រើសរើសនាយកមុន ។ មតិភាគច្រើន នៃការបោះឆ្នោតនឹងត្រូវសំរាប់ការបោះឆ្នោត ។ នៅពេលដែលតំណែងស្ថិតនៅទំនេរ អ្នកជំនួសរបស់នាយកមុន នឹងត្រូវអនុវត្តអំណាចជំនួស លើកលែងតែត្រូវបានតែងតាំងអ្នកជំនួសម្នាក់ទៀត ។

មាត្រា ៤២ : ការបោះឆ្នោត ក្នុងគណៈកម្មការ

ក- នាយកនីមួយៗត្រូវបានចាត់តាំងឱ្យបោះឆ្នោតនូវចំនួនសំឡេងរបស់សមាជិក ដែលសំឡេងឆ្នោតត្រូវរាប់សំរាប់ការជ្រើសរើសនាយកនោះ ។ គ្រប់សំឡេងដែលនាយកម្នាក់ត្រូវបានចាត់តាំងឱ្យបោះត្រូវបានបោះជាឯកតា ។ លើកលែងតែបានចែងដោយឡែកនៅក្នុងអនុសញ្ញានេះ សេចក្តីសំរេចចិត្តរបស់គណៈកម្មការ ត្រូវបានធ្វើដោយភាគច្រើននៃសំឡេងឆ្នោត ។

ខ- កូរ៉ុំ សំរាប់ការបោះឆ្នោតត្រូវបង្កើតដោយភាគច្រើននៃនាយកដែលមានចំនួនមិនតិចជាងពាក់កណ្តាល នៃអំណាចបោះឆ្នោតសរុប ។

គ- តាមបទបញ្ញត្តិ គណៈកម្មការអាចបង្កើតវិធីចាត់ការ ដោយប្រធាន ( Chairman ) អាចសុំសេចក្តីសំរេចរបស់គណៈកម្មលើបញ្ហាពិសេសដោយឡែក ដោយមិនបាច់កោះប្រជុំគណៈកម្មការនៅពេលដែលគេយល់ថា សកម្មភាពរបៀបនេះ មានផលប្រយោជន៍ល្អបំផុតសំរាប់ទីភ្នាក់ងារ ។

# ជំពូក VII
## ឯកសិទ្ធិ និង អភ័យឯកសិទ្ធិ
## ( Privileges and Immunities )

មាត្រា ៤៣ : គោលបំណងនៃជំពូក

ដើម្បីជួយដល់ទីភ្នាក់ងារ ឱ្យបំពេញមុខងាររបស់ខ្លួនបាន អភ័យឯកសិទ្ធិ និងឯកសិទ្ធិ ដែលចែងនៅក្នុងជំពូកនេះ នឹងត្រូវអនុញ្ញាតឱ្យទីភ្នាក់ងារនៅក្នុងទឹកដីនៃសមាជិកនីមួយៗ ។

មាត្រា ៤៤ : រឿងក្តី ( Legal Process )

សកម្មភាព ក្រៅពីអ្វីដែលបានចែងក្នុងមាត្រា ៥៧ និង ៥៨ អាចមកយកប្រឆាំងនឹងទីភ្នាក់ងារបាន មានតែនៅក្នុងតុលាការយុត្តាធិការ ដែលមានសមត្ថកិច្ចនៅក្នុងទឹកដីនៃសមាជិកមួយ ដែលនៅក្នុងទឹកដីនោះមាន ការិយាល័យរបស់ទីភ្នាក់ងារ ឬក៏តែងតាំងភ្នាក់ងារមួយ សំរាប់គោលបំណងទទួល Service និង Notice នៃរឿងក្តី ។ គ្មានសកម្មភាពប្រឆាំងណាមួយទល់នឹងទីភ្នាក់ងារ អាចធ្វើបាន ដោយសមាជិក ឬបុគ្គល ដែលធ្វើអំពើសំរាប់ ឬធ្វើឱ្យទៅជាការទាមទារសំណងពីសមាជិក ឬ ដោយកិច្ចការផ្ទាល់ខ្លួន ។ កម្មសិទ្ធិ និងទ្រព្យសម្បត្តិរបស់ទីភ្នាក់ងារ ទោះបីជានៅទីណា និងកាន់កាប់ដោយអ្នកណានឹងត្រូវមានអភ័យឯកសិទ្ធិ រួចផុតពីរាល់រូបភាព ចាប់យក រឹបអូស ឬ Excution មុនពេលចេញការវិនិច្ឆ័យសំរេចចុងក្រោយ ឬសាលក្រមប្រឆាំងនឹងទីភ្នាក់ងារ ។

មាត្រា ៤៥ : ទ្រព្យសម្បត្តិ

ក- កម្មសិទ្ធិ និងទ្រព្យរបស់ទីភ្នាក់ងារ ទោះបីជាស្ថិតនៅទីណា និងកាន់កាប់ដោយអ្នកណានឹងត្រូវមានអភ័យឯកសិទ្ធិ រួចផុតពីការរុករក ទាមទាររឹបអូស ដកហូត ឬរូបភាពណាមួយផ្សេងទៀតនៃការរឹបអូសដោយសកម្មភាពនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ។

ខ- ដើម្បីពង្រីកការចាំបាច់សំរាប់ធ្វើប្រតិបត្តិការតាមអនុសញ្ញានេះ កម្មសិទ្ធិ និងទ្រព្យសម្បត្តិទាំងអស់របស់ទីភ្នាក់ងារ នឹងរួចផុតពីការដាក់កំរិតបញ្ញត្តិ ត្រួតពិនិត្យ និងផ្អាកសកម្មភាពគ្រប់ប្រភេទ ដែលថាកម្មសិទ្ធិ និងទ្រព្យសម្បត្តិដែលបានទទួលមកដោយទីភ្នាក់ងារ ដែលជាអ្នកបន្តទៅឱ្យ ឬអ្នកតំណាង ( Subbrogce ) របស់អ្នកដែលបានទទួលការធានា អង្គភាពរ៉ាប់រងជាថ្មី ឬវិនិយោគិនដែលរ៉ាប់រងដោយអង្គភាពរ៉ាប់រងជាថ្មី ត្រូវបានរួចផុតពីការដាក់កំរិតប្តូររូបិយវត្ថុបរទេស ការដាក់បញ្ញត្តិ និងត្រួតពិនិត្យដោយបង្ខំ នៅក្នុងទឹកដីនៃសមាជិក ដែលពាក់ព័ន្ធទៅនឹងអ្នកទទួល អង្គភាព ឬវិនិយោគិន ដែលចំពោះអ្នកទាំងនេះ ទីភ្នាក់ងារត្រូវតំណាងឱ្យ ត្រូវបានតាំងចំពោះកិច្ចការរបៀបនេះ ។

គ- សំរាប់គោលបំណងនៃជំពូកនេះ ពាក្យថា "ទ្រព្យសម្បត្តិ" នឹងរាប់បញ្ចូលទាំងទ្រព្យសម្បត្តិនៃមូលនិធិទុកចិត្តបើកការធានា ( Sponsorship Trust Funol ) ដែលបានបង្កើតនៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ និងទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយទីភ្នាក់ងារ ។

មាត្រា ៤៦ : បណ្ណសារដ្ឋាន និងទំនាក់ទំនង ( Archives and Communications)

ក- បណ្ណសារដ្ឋានរបស់ទីភ្នាក់ងារ នឹងមិនអាចរំលោភបានទោះបីជានៅទីណាក៏ដោយ ។

ខ- ទំនាក់ទំនងផ្លូវការរបស់ទីភ្នាក់ងារ នឹងត្រូវបានយល់ព្រមដោយសមាជិកនីមួយៗ ដូចគ្នានឹងអ្វីដែលបានយល់ព្រមចំពោះទំនាក់ទំនងផ្លូវការរបស់ធនាគារ ។

មាត្រា ៤៧ : ពន្ធ ( Taxes )

ក- ទីភ្នាក់ងារ ទ្រព្យសម្បត្តិ កម្មសិទ្ធិ និងចំណូល និងប្រតិបត្តិការរបស់ទីភ្នាក់ងារ និងកិច្ចការបំពេញដែលអនុញ្ញាតដោយអនុសញ្ញានេះ នឹងត្រូវបានរួចផុតពីពន្ធអាករ ( Taxes) និងពន្ធគយ ~~( Customs duties ) ។ ទីភ្នាក់ងារ~~ នឹងបានរួចផុតពីភាពទទួលខុសត្រូវចំពោះការប្រមូល ឬការបង់ចំពោះពន្ធអាករ ឬពន្ធគយណាមួយ ។

ខ- លើកលែងតែក្នុងករណីជាតិនៅទីនោះ នឹងមិនត្រូវប្រមូលពន្ធលើការចំណាយសោធន ដែលបង់ដោយទីភ្នាក់ងារចំពោះអភិបាល និងអ្នកជំនួស ឬក៏ចំពោះប្រាក់ខែ ចំណាយសោធន ឬការផ្សេងៗ ដែលទីភ្នាក់ងារបង់ចំពោះ ប្រធានគណៈកម្មការ នាយក អ្នកជំនួស ប្រធាន និងបុគ្គលិកនៃទីភ្នាក់ងារឡើយ ។

គ- គ្មានការយកពន្ធគ្រប់ប្រភេទ ចំពោះការវិនិយោគដែលបានធានា ឬរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ (គិតទាំងប្រាក់ដែលរកបានពីនោះ) ឬនយោបាយរ៉ាប់រង ដែលរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ (គិតទាំងប្រាក់កំរៃ និងចំណូលដែលបានពីនោះ) ទោះបីដោយរបៀបណា (១) ដែលរើសអើងចំពោះការវិនិយោគនេះ ឬនយោបាយរ៉ាប់រង តែម្នាក់ឯងពីព្រោះតែវាត្រូវបានធានា ឬរ៉ាប់រងជាថ្មីដោយទីភ្នាក់ងារ ឬ(២) ប្រសិនបើមូលដ្ឋានច្បាប់តែមួយគត់របស់ការយកពន្ធនេះ គឺការតាំងការិយាល័យ ឬទីកន្លែងអាជីវកម្ម ដែលកាន់កាប់ដោយទីភ្នាក់ងារ ។

មាត្រា ៤៨ : មន្ត្រីផ្លូវការរបស់ទីភ្នាក់ងារ ( Officials of Agency ) អភិបាល នាយក អ្នកជំនួស ប្រធានគណៈកម្មការ ( President ) និងបុគ្គលិកទីភ្នាក់ងារទាំងអស់ ។

១- នឹងរួចផុតពីការកាត់ក្តី ចំពោះសកម្មភាពដែលគេបានធ្វើក្នុងសមត្ថកិច្ចផ្លូវការ ។

២- មិនមែនជាជនជាតិនៅទីនោះ ក៏នឹងទទួលនូវអភ័យឯកសិទ្ធិដូចគ្នាពីការរឹតត្បិតអន្តោប្រវេសន៍ ការទាមទារចុះឈ្មោះជនបរទេស និងកាតព្វកិច្ចបំរើជាតិ និងទទួលការងាយស្រួលដូចគ្នាចំពោះការរឹតត្បិតប្តូររូបិយវត្ថុ ដូចដែលបានយល់ព្រមដោយសមាជិកពាក់ព័ន្ធចំពោះអ្នកតំណាង មន្ត្រីផ្លូវការ និងនិយោជិក ដែលមានឋានៈប្រហាក់ប្រហែលនៃសមាជិកដទៃ ។

៣- ត្រូវបានធានាដោយគោលការណ៍ដូចគ្នា ចំពោះការសម្រួលក្នុងការធ្វើដំណើរ ដូចដែលបានយល់ព្រមដោយសមាជិកពាក់ព័ន្ធចំពោះអ្នកតំណាងមន្ត្រីផ្សេងៗ និងនិយោជិតដែលមានឋានៈប្រហាក់ប្រហែលនៃសមាជិកដទៃទៀត ។

មាត្រា ៤៩ : ការអនុវត្តន៍នៃជំពូកនេះ

សមាជិកនិមួយៗ នឹងធ្វើសកម្មភាពតាមការចាំបាច់នៅក្នុងទឹកដីរបស់ខ្លួន ក្នុងគោលបំណងធ្វើឱ្យមានប្រសិទ្ធិភាព ក្នុងអាណាគ្គិច្បាប់របស់ខ្លួន នូវគោលការណ៍ដែលបានចែងនៅក្នុងជំពូកនេះ និងផ្តល់ពត៌មានដល់ទីភ្នាក់ងារអំពីសកម្មភាពលំអិតដែលបានធ្វើ ។

មាត្រា ៥០ : ការបដិសេធ ( Waiver )

អភ័យឯកសិទ្ធិ អញ្ញត្រកម្ម ( Exemptiens ) និងឯកសិទ្ធិដែលចែងនៅក្នុងជំពូកនេះ ត្រូវបានធានា ដើម្បីផលប្រយោជន៍របស់ទីភ្នាក់ងារ ហើយអាចត្រូវបានបដិសេធ ចំពោះព្រំដែន និងអាស្រ័យលើលក្ខខណ្ឌដែលអាចកំណត់ដោយទីភ្នាក់ងារ ក្នុងករណីដែលការបដិសេធនេះ មិនធ្វើឱ្យខូចផលប្រយោជន៍របស់ខ្លួន ។ ទីភ្នាក់ងារ និងបដិសេធអភ័យឯកសិទ្ធិរបស់បុគ្គលខ្លួនណាម្នាក់ ក្នុងករណីដែល តាមយោបល់របស់ខ្លួន ថាអភ័យឯកសិទ្ធិនេះអាចបង្អាក់ដល់ភាពយុត្តិធម៌ និងអាចត្រូវបានបដិសេធដោយមិនធ្វើឱ្យខូចផលប្រយោជន៍របស់ទីភ្នាក់ងារ ។

## ជំពូក VIII

## ការដកខ្លួនចេញ ការផ្អាក សមាជិកភាព និងការបញ្ឈប់ប្រតិបត្តិការ

មាត្រា ៥១ : ការដកខ្លួនចេញ ( With drawal )

សមាជិកណាមួយ បន្ទាប់ពីការផុតកំណត់ពេលបីឆ្នាំ បន្ទាប់ពីថ្ងៃដែលអនុសញ្ញាបានចូលជាធរមានចំពោះសមាជិកនោះ អាចដកខ្លួនចេញពីទីភ្នាក់ងារនៅពេលណាក៏បាន ដោយប្រគល់លិខិតជូនដំណឹងចំពោះទីភ្នាក់ងារ នៅការិយាល័យធំ ។ ទីភ្នាក់ងារ នឹងជូនដំណឹងដល់ធនាគារ ដែលជាទីកន្លែងទុកដាក់អនុសញ្ញានេះ អំពីការទទួលនូវលិខិតជូនដំណឹងនេះ ។ ការដកខ្លួនចេញណាមួយ នឹងមានប្រសិទ្ធភាព កៅសិបថ្ងៃបន្ទាប់ពីថ្ងៃដែលទីភ្នាក់ងារបានទទួលលិខិតជូនដំណឹងនេះ ។ សមាជិកអាចដកយកលិខិតជូនដំណឹងនេះមកវិញ មុនពេលដែលក្លាយទៅជាប្រសិទ្ធិភាព ។

មាត្រា ៥២ : ការផ្អាក សមាជិកភាព ( Suspension of Membership )

ក- ប្រសិនបើសមាជិកណាម្នាក់ មិនគោរពតាមកាតព្វកិច្ចណាមួយរបស់ខ្លួន នៅតាមអនុសញ្ញានេះ ដោយមតិភាគច្រើនរបស់សមាជិក ដែលអនុវត្តមតិភាគច្រើននៃអំណាចបោះឆ្នោតសរុប ក្រុមប្រឹក្សាអាចផ្អាក សមាជិកភាពបាន ។

ខ- ក្នុងរយៈពេលផ្អាក សមាជិកមិនមានសិទ្ធិតាមអនុសញ្ញានេះទេ លើកលែងតែសិទ្ធិក្នុងការដកខ្លួនចេញ និងសិទ្ធិផ្សេងទៀតដែលចែងនៅក្នុងជំពូកនេះ និងជំពូក IX ក៏ប៉ុន្តែនឹងរក្សាកម្មវត្ថុចំពោះការតព្វកិច្ចទាំងអស់របស់ខ្លួន ។

គ- សំរាប់គោលបំណងនៃការកំណត់ភាពដែលអាចជ្រើសយកបានសំរាប់ការធានា ឬរ៉ាប់រងជាថ្មី ដែលបានចែងនៅក្នុងជំពូក III ឬឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ សមាជិកដែលត្រូវផ្អាកមិនត្រូវបានប្រព្រឹត្តិចំពោះ ដូចជាសមាជិករបស់ទីភ្នាក់ងារទេ ។

ឃ- សមាជិកដែលត្រូវផ្អាក នឹងត្រូវបញ្ឈប់លែងជាសមាជិកដោយស្វ័យប្រវត្តិ មួយឆ្នាំបន្ទាប់ពីថ្ងៃផ្អាក លើកលែងតែក្រុមប្រឹក្សាសំរេចពន្យារពេលផ្អាក ឬក៏ធ្វើបដិទានសមាជិកឡើងវិញ ។

មាត្រា ៥៣ : សិទ្ធិ និងការកិច្ច ( Duties ) នៃរដ្ឋដែលឈប់លែងជាសមាជិក

ក- នៅពេលដែលរដ្ឋមួយឈប់លែងជាសមាជិក រដ្ឋនេះនឹងនៅតែទទួលខុសត្រូវចំពោះរាល់ការតព្វកិច្ចរបស់ខ្លួន គិតទាំងការតព្វកិច្ចមិនបានគ្រោងទុកតាមអនុសញ្ញានេះ ដែលនឹងមានប្រសិទ្ធិភាពមុនពេលបញ្ឈប់សមាជិកភាពរបស់ខ្លួន ។

ខ- ដោយមិនធ្វើឱ្យខូចខាតដល់ផ្នែក (ក) ខាងលើទីភ្នាក់ងារ នឹងចាត់ចែងជាមួយរដ្ឋនោះសំរាប់ការយល់ព្រមលើការទាមទារ និងការតព្វកិច្ច ។ ការចាត់ចែងរបៀបនេះណាមួយ នឹងត្រូវបានយល់ព្រមពីគណៈកម្មការ ។

មាត្រា ៥៤ : ការផ្អាកប្រតិបត្តិការ ( Suspension of Operations )

ក- នៅពេលដែលបានគិតថាជាការត្រឹមត្រូវ គណៈកម្មការអាចផ្អាកចេញការធានាថ្មី សំរាប់រយៈពេលពិសេសមួយ ។

ខ- ក្នុងពេលមានអាសន្ន គណៈកម្មការអាចផ្អាករាល់សកម្មភាពរបស់ទីភ្នាក់ងារ សំរាប់រយៈពេលមួយ ដែលមិនហួសរយៈពេលអាសន្ននេះ ផ្តល់នូវការចាត់ចែងចាំបាច់ ដែលនឹងធ្វើដើម្បីការពារផលប្រយោជន៍របស់ទីភ្នាក់ងារ និងភាគីទីបី ។

គ- ការសំរេចចិត្តផ្អាកប្រតិបត្តិការ នឹងមិនមានប្រសិទ្ធិភាពលើការតព្វកិច្ចរបស់សមាជិក ក្នុងអនុសញ្ញានេះ ឬលើការតព្វកិច្ចរបស់ទីភ្នាក់ងារចំពោះអ្នកដែលបានទទួលការធានា ឬប័ណ្ណរ៉ាប់រងជាថ្មី ឬចំពោះភាគីទីបី ។

មាត្រា ៥៥ : ការរំសាយ ( Liquidation )

ក- ក្រុមប្រឹក្សាដោយភាគច្រើនពិសេស អាចសំរេចបញ្ឈប់ប្រតិបត្តិការ រំលាយទីភ្នាក់ងារ ទីភ្នាក់ងារ នឹងបញ្ឈប់ភ្លាមរាល់សកម្មភាព លើកលែងតែអ្វីដែលអាចកើតឡើងដើម្បីធ្វើឱ្យរៀបរយ ការថែរក្សា និងការបម្រុងទុក នូវទ្រព្យសម្បត្តិ និងធ្វើឱ្យរៀបរយនូវកាតព្វកិច្ច ។ រហូតដល់មានការរៀបរយ និងបែងចែកទ្រព្យសម្បត្តិ ទីភ្នាក់ងារនឹងរក្សាអត្ថិភាព ហើយរាល់សិទ្ធិនិងការកាតព្វកិច្ចរបស់សមាជិកក្នុងអនុសញ្ញា នឹងនៅបន្តដោយមិនបន្ថយ ។

ខ- គ្មានការបែងចែកទ្រព្យសម្បត្តិ នឹងត្រូវធ្វើចំពោះសមាជិកឡើងរហូតដល់រាល់ការទទួលខុសត្រូវចំពោះអ្នកដែលបានទទួលការធានា និងឥណទាយកត្រូវបានទូទាត់ ឬផ្តល់ឱ្យនិងរហូតដល់ក្រុមប្រឹក្សាសំរេចចិត្តថានឹងធ្វើការបែងចែក ។

គម្រវត្ថុចំពោះអ្វីដែលមានពីមុនមក ទីភ្នាក់ងារនឹងបែងចែក ទ្រព្យសម្បត្តិដែលនៅសល់របស់ខ្លួនចំពោះសមាជិក តាមសមាមាត្រនៃភាគហ៊ុនរបស់សមាជិកនីមួយៗ នៅក្នុងដើមទុនដែលបានចុះឈ្មោះ ។ ទីភ្នាក់ងារនឹងបែងចែកផងដែរ នូវទ្រព្យសម្បត្តិដែលនៅសល់របស់ Sponsorship Trust Fund ដែលយោងនៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ ចំពោះសមាជិកដែល ធ្វើការធានាតាមសមាមាត្រដែលវិនិយោគត្រូវបានធានា ដោយភាគហ៊ុននីមួយៗ ( Bears ) ចំពោះ ការវិនិយោគ ដែលបានទទួលការធានាសរុបទាំងអស់ ។ គ្មានសមាជិកណាមួយនឹងត្រូវបានទាត់ជា តំណាងភាគហ៊ុននៅក្នុងទ្រព្យសម្បត្តិរបស់ទីភ្នាក់ងារឬ Sponsor-ship Trust Fund លើកលែងតែសមាជិកនោះ បានសងប្រាក់ចំពោះរាល់ការទាមទារដោយទីភ្នាក់ងារ ។ រាល់ការបែងចែកត្រូវធ្វើនៅពេលណាមួយ ដែលក្រុមប្រឹក្សានឹងកំណត់តាមរបៀបដែលគេគិតថាយុត្តិធម៌ និងស្មើភាព ។

## ជំពូក IX

## ដំណោះស្រាយជំលោះ

## (Settlement of Disputies)

មាត្រា ៥៦ : ការបកស្រាយ និងការអនុវត្តន៍អនុសញ្ញា

ក- បញ្ហាណាមួយនៃការបកស្រាយ ឬអនុវត្តនូវ (ខ) កំណត់នៃអនុសញ្ញា ដែលលេចឡើងរវាងសមាជិកណាមួយនៃទីភ្នាក់ងារ ជាមួយទីភ្នាក់ងារ ឬក្នុងចំណោមសមាជិកនៃទីភ្នាក់ងារ នឹងត្រូវដាក់ជូនគណៈកម្មការដើម្បីសំរេច ។ សមាជិកមួយដែលប៉ះពាល់ជាពិសេសជាមួយបញ្ហា និងដែលមិនមាន

តំណាងដោយជាតិណាមួយនៅក្នុងគណៈកម្មការអាចបញ្ជូនអ្នកតំណាង ទៅចូលរួមការប្រជុំរបស់គណៈកម្មការ ដែលនឹងលើកយកបញ្ហានោះមកពិចារណា ។

ខ- ក្នុងករណីដែលគណៈកម្មការបានឱ្យសេចក្តីសំរេចតាមផ្នែក (ក) ខាងលើ សមាជិកណាមួយអាចស្នើសុំឱ្យយកបញ្ហានេះទៅជូនក្រុមប្រឹក្សា ដែលសេចក្តីសំរេច នឹងត្រូវជាសេចក្តីសំរេចចុងក្រោយ ។ ក្នុងពេលដែលកំពុងរង់ចាំលទ្ធផលពីក្រុមប្រឹក្សា ប្រសិនបើចាំបាច់ ទីភ្នាក់ងារអាចប្រព្រឹត្តនៅលើមូលដ្ឋាននៃសេចក្តីសំរេចរបស់គណៈកម្មការ ។

មាត្រា ៥៧ : ជំលោះស្រាយរវាងទីភ្នាក់ងារ និងសមាជិក

ក- ដោយមិនធ្វើឱ្យខូចខាតដល់ (ខ) កំណត់នៃមាត្រា ៥៦ និងផ្នែក (ខ) នៃមាត្រានេះ ជំលោះណាមួយរវាងទីភ្នាក់ងារ និងសមាជិកមួយ ឬទីភ្នាក់ងារពាក់ព័ន្ធមួយ និងជំលោះណាមួយរវាងទីភ្នាក់ងារ និងប្រទេសមួយ (ឬទីភ្នាក់ងារពាក់ព័ន្ធ) ដែលបានឈប់ឡើងជាសមាជិក នឹងត្រូវបានដោះស្រាយអនុលោម ទៅតាមវិធីចាត់ការដែលបានចេញនៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញានេះ ។

ខ- ជំលោះដែលទាក់ទង នឹងការទាមទាររបស់ទីភ្នាក់ងារ ដែលសំដែងតួជាអ្នកតំណាងវិនិយោគិនមួយ នឹងត្រូវបានដោះស្រាយអនុលោមតាម ឬមួយ(១) ដោយវិធីចាត់ការដែលដាក់ចេញនៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញានេះ ឬ(២) ការព្រមព្រៀងរវាងទីភ្នាក់ងារ និងសមាជិកពាក់ព័ន្ធដែលទទួលយកវិធីដែលអាចជ្រើសយកបាន ឬវិធីសំរាប់ដំណោះស្រាយជំលោះរបៀបនេះ ក្នុងករណីចុងក្រោយ ឧបសម្ព័ន្ធទី ២ នៃអនុសញ្ញានេះនឹងប្រើសំរាប់ជាមូលដ្ឋាន សំរាប់ការព្រមព្រៀងដែលក្នុងករណីនីមួយៗ នឹងត្រូវបានយល់ព្រមដោយគណៈកម្មការ ដោយភាគច្រើនពិសេសនឹងទទួលធ្វើដោយទីភ្នាក់ងារ នូវប្រតិបត្តិការនៅក្នុងទឹកដីនៃសមាជិកពាក់ព័ន្ធ ។

មាត្រា ៥៨ : ជំលោះដែលទាក់ទងនឹងបណ្តាអ្នកដែលបានទទួលការធានា ឬរ៉ាប់រងជាថ្មី

ជំលោះណាមួយដែលកើតឡើងដោយកិច្ចសន្យានិងការធានា ឬរ៉ាប់រងជាថ្មីរវាងភាគីជំលោះនេះ នឹងត្រូវដាក់ជូនទៅការកាត់សេចក្តីដោយតុលាការ សំរាប់ការកំណត់ចុងក្រោយ ដោយអនុលោមតាមច្បាប់នេះ ដូចដែលនឹងកំណត់សំរាប់ ឬទៅកិច្ចសន្យា នៃការធានា ឬរ៉ាប់រងជាថ្មី។

## ជំពូក X
## វិសោធនកម្ម
## (Amendments)

មាត្រា ៥៩ : វិសោធនកម្មដោយក្រុមប្រឹក្សា

ក- អនុសញ្ញានេះ និងឧបសម្ព័ន្ធអាចត្រូវបានធ្វើវិសោធនកម្មដោយសំឡេងយល់ព្រម បីភាគបួនរបស់អភិបាល ដែលមានចំនួនបួនភាគប្រាំនៃអំណាចបោះឆ្នោតសរុប កំណត់ថា :

១- វិសោធនកម្មណាមួយដែលកែប្រែសិទ្ធិដកខ្លួនចេញពីទីភ្នាក់ងារ ដែលបានកំណត់ក្នុងមាត្រា ៥១ ឬការកំរិតភាពទទួលខុសត្រូវ ដែលកំណត់ក្នុងផ្នែក (ឃ)មាត្រា ៨ នឹងត្រូវការសំឡេងយល់ព្រមពីអភិបាលទាំងអស់ និង

២- វិសោធកម្មណាមួយ ដែលកែប្រែការរៀបចំភាគហ៊ុនដែលបាត់បង់កំណត់នៅក្នុងមាត្រា ១ និង ៣ នៃឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ ដែលនឹងធ្វើឱ្យកើនទ្វេភាពទទួលខុសត្រូវរបស់សមាជិកណាមួយខាងក្រោមនោះ នឹងត្រូវការសំឡេងយល់ព្រមពីអភិបាលនៃសមាជិកនិមួយៗនោះ ។

ខ- គារាង (ក) និង (ខ) នៃអនុសញ្ញានេះ អាចធ្វើវិសោធនកម្មដោយក្រុមប្រឹក្សា ដោយភាគច្រើនពិសេស ។

គ- ប្រសិនបើវិសោធនកម្មមួយ ប៉ះពាល់នឹងបញ្ញត្តិណាមួយនៃឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ សំឡេងសរុបនឹងបូកបញ្ចូលសំឡេងបន្ថែម ( Additional votes ) ដែលមានចែងក្នុងមាត្រា ៧ នៃឧបសម្ព័ន្ធនេះ ចំពោះសមាជិកដែលបានធានានិងប្រទេសម្ចាស់ផ្ទះ នៃវិនិយោគដែលត្រូវបានធានា ។

មាត្រា ៦០ : វិធីដំណើរការ ( Procedure )

សំណើរណាមួយដើម្បីធ្វើវិសោធ កម្មអនុសញ្ញានេះ ទោះបីចេញពីសមាជិកម្នាក់ អភិបាលម្នាក់ ឬនាយកម្នាក់ នឹងត្រូវបានទាក់ទងទៅប្រធានគណៈកម្មការ ដែលនឹងនាំយកសំណើរទៅដាក់ជូនគណៈកម្មការ ។ ប្រសិនបើវិសោធនកម្មដែលបានស្នើនោះ ត្រូវបានគណៈកម្មការយល់ថា គួរទទួលយកបាន វានឹងត្រូវដាក់ជូនក្រុមប្រឹក្សាដើម្បីសំរេចយល់ព្រមអនុលោមតាមមាត្រា ៥៩ ។ នៅពេលដែលវិសោធនកម្មត្រូវបានយល់ព្រម ដោយត្រឹមត្រូវពីក្រុមប្រឹក្សាហើយ ទីភ្នាក់ងារនឹងបញ្ជាក់តាមទំនាក់ទំនងផ្លូវការចំពោះសមាជិកទាំងអស់ ។ វិសោធនកម្មនឹងចូលជាធរមានសំរាប់សមាជិកទាំងអស់ ក្នុងរយៈពេលកៅសិបថ្ងៃបន្ទាប់ ពីថ្ងៃទំនាក់ទំនងផ្លូវការ លើកលែងតែក្រុមប្រឹក្សានឹងបញ្ជាក់ថ្ងៃផ្សេងពីនេះ ។

## ជំពូក XI

## បញ្ញត្តិចុងក្រោយ (Final Provisions)

មាត្រា ៦១ : ការចូលជាធរមាន

ក- អនុសញ្ញានេះនឹងបើកចំហ សំរាប់ការចុះហត្ថលេខាចំពោះសមាជិកទាំងអស់នៃធនាគារ និងប្រទេសស្វីស ហើយនឹងជាកម្មវត្ថុសំរាប់សច្ចាប័នការទទួល ឬយល់ព្រមដោយរដ្ឋហត្ថលេខី អនុលោមជាមួយវិធីដំណើរការធម្មនុញ្ញ ( Constitutional Procedures ) ។

ខ- អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃដែលសារលិខិត ( Instrument ) មិនតិចជាងប្រាំនៃសច្ចាប័ន ការទទួល ឬយល់ព្រមនឹងត្រូវបានតម្កល់ទុកចំពោះរដ្ឋហត្ថលេខី នៃប្រភេទទី ១ និងសារលិខិតមិនតិចជាងដប់ប្រាំ នឹងត្រូវបានតម្កល់ទុកចំពោះរដ្ឋហត្ថលេខីប្រភេទទី ២ កំណត់ថាចំនួនជាសរុបនៃរដ្ឋទាំងនេះ មិនតិចជាងមួយភាគបីនៃដើមទុន ដែលបានអនុញ្ញាតិរបស់ទីភ្នាក់ងារ ដូចដែលបានកំណត់នៅក្នុងមាត្រា ៥ ។

គ- ចំពោះរដ្ឋនីមួយៗ ដែលតម្កល់សារលិខិតសំរាប់សច្ចាប័ន ការទទួល ឬយល់ព្រមបន្ទាប់ពីអនុសញ្ញានេះ នឹងបានចូលជាធរមាន អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃដែលបានដាក់តម្កល់ ។

ឃ- ប្រសិនបើអនុសញ្ញានេះ មិនបានចូលជាធរមានក្នុងរវាងពីរឆ្នាំបន្ទាប់ពីការបើកចំហ ឱ្យចុះហត្ថលេខា ប្រធានធនាគារនឹងកោះធ្វើសន្និសិទ្ទិសំរាប់ប្រទេសដែលចាប់អារម្មណ៍ ដើម្បីកំណត់ពីមាគ៌ាអនាគតនៃសកម្មភាព ។

មាត្រា ៦២ : ការប្រជុំសម្ភោធ ( Inaupural Meeting )

យោលទៅលើការចូលជាធរមាននៃអនុសញ្ញានេះ ប្រធានធនាគារនឹងកោះប្រជុំសម្ភោធក្រុមប្រឹក្សា ។ ការប្រជុំនេះ និងធ្វើនៅការិយាល័យធំនៃទីភ្នាក់ងារ ក្នុងរវាងហុកសិបថ្ងៃ គិតចាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន ឬអាចឆាប់ជាងនេះ តាមដែលអាចធ្វើទៅបាន ។

មាត្រា ៦៣ : ទីកន្លែងតម្កល់ទុក ( Depoditory )

សារលិខិតនៃសច្ចាប័ន ការទទួល ឬយល់ព្រមនៃអនុសញ្ញានេះ និងវិសោធនកម្ម នឹងត្រូវតម្កល់ទុកជាមួយធនាគារ ដែលនឹងដើរតួជាកន្លែងតម្កល់ទុកនៃអនុសញ្ញានេះ ។ ទីកន្លែងតម្កល់ទុកនឹងបញ្ជូនច្បាប់ចម្លងដែលបានបញ្ជាក់នៃអនុសញ្ញានេះ ទៅរដ្ឋសមាជិកនៃធនាគារ និងប្រទេសស្វីស ។

មាត្រា ៦៤ : ការចុះបញ្ជី ( Regiotration )

ទីកន្លែងតម្កល់ទុក នឹងចុះបញ្ជីអនុសញ្ញានេះ ជាមួយលេខាធិការដ្ឋាននៃសហប្រជាជាតិ អនុលោមតាមមាត្រា ១០២ នៃសារលិខិតអនុញ្ញាតិកម្មសិទ្ធិ របស់សហប្រជាជាតិ និងបទបញ្ញត្តិខាងក្រោមនោះ ដែលនឹងត្រូវទទួលយកដោយសម័យប្រជុំទូទៅ ( General Assembly ) ។

មាត្រា ៦៥ : កំណត់សម្គាល់ ( Notification )

ទីកន្លែងតម្កល់នឹងកត់សំគាល់រដ្ឋហត្ថលេខីទាំងអស់ និងទីភ្នាក់ងារដោយឈរលើការចូលជាធរមាននៃអនុសញ្ញា ដូចខាងក្រោមនេះ :

១- ហត្ថលេខា នៃអនុសញ្ញានេះ

២- តម្កល់ទុកសារលិខិតនៃសច្ចាប័ន ការទទួល និងយល់ព្រម អនុលោមតាមមាត្រា ៦១

៣- កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន អនុលោមតាមមាត្រា ៦១

៤- ការបណ្តេញចេញពីការអនុវត្តន៍ដែនដី (Territorial application) ស្របតាមមាត្រា ៦៦ និង

៥- ការដកខ្លួនចេញនៃសមាជិកពីទីភ្នាក់ងារ តាមមាត្រា ៥១ ។

មាត្រា ៦៦ : ការអនុវត្តន៍ដែនដី (Territorial application)

អនុសញ្ញានេះនឹងអនុវត្តចំពោះទឹកដីទាំងអស់ ដែលស្ថិតនៅក្រោមអំណាចច្បាប់របស់ សមាជិក គិតទាំងទឹកដីសំរាប់ទំនាក់ទំនងអន្តរជាតិ ដែលសមាជិកទទួលខុសត្រូវ លើកលែងតែទឹកដីដែលសមាជិកបានដកចេញ ដោយលិខិតជាលាយលក្ខណ៍អក្សរ ចំពោះទីកន្លែងតម្កល់ទុកនៃអនុសញ្ញានេះ នោះបីជានៅពេលនៃសច្ចាប័ន ការទទួល ឬយល់ព្រម ឬនៅគ្រាក្រោយមក ។

មាត្រា ៦៧ : ការត្រួតពិនិត្យជាចន្លោះពេល ( Periodic rviews )

ក- ក្រុមប្រឹក្សានឹងធ្វើការត្រួតពិនិត្យ ស្វែងយល់ ជាចន្លោះពេលនូវសមត្ថភាពរបស់ទីភ្នាក់ងារ ក៏ដូចជាលទ្ធផល ដែលប្រមូលយកបាន ដើម្បីនាំទៅដល់ការកែប្រែ សំដៅបង្កើនសកម្មភាពរបស់ទីភ្នាក់ងារ ដើម្បីបំរើគោលដៅរបស់ខ្លួន ។

ខ- ការត្រួតពិនិត្យរបៀបនេះ លើកទីមួយ នឹងធ្វើនៅរយៈពេលប្រាំឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ។ កាលបរិច្ឆេទនៃការត្រួតពិនិត្យបន្តទៅទៀត នឹងត្រូវកំណត់ដោយក្រុមប្រឹក្សា ។

ធ្វើនៅសេអ៊ូលតែមួយច្បាប់ ដែលនឹងតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋាននៃធនាគារអន្តរជាតិសំរាប់កសាង និងអភិវឌ្ឍន៍ដែលនឹងបញ្ជាក់ដោយហត្ថលេខាខាងក្រោម ពីការព្រមព្រៀងបំពេញមុខងារដែលត្រូវប្រគល់ឱ្យដោយអនុសញ្ញានេះ ។

ឧបសម្ព័ន្ធទី១

ការធានាចំពោះការវិនិយោគដែលមានការធានា ក្រោមមាត្រា ២៤

មាត្រា ១ - ធានាភាព ( Sponsorship )

ក- សមាជិកណាមួយអាចធានា សំរាប់ការធានាលើការវិនិយោគមួយដែលត្រូវធ្វើឡើង ដោយវិនិយោគិននៃសញ្ជាតិណាមួយ ឬដោយបណ្តាវិនិយោគិន នៃសញ្ជាតិណាមួយឬច្រើន ។

ខ- កម្មវត្ថុនៃបទបញ្ញត្តិ នៃផ្នែក ( ខ ) និង ( គ ) នៃមាត្រា ៣ នៃឧបសម្ព័ន្ធនេះ សមាជិកដែលធានានីមួយៗនឹងបែងចែក ជាមួយសមាជិកដែលធានាដទៃទៀត ចំពោះការ បាត់បង់ក្រោមការធានា នៃវិនិយោគដែលបានទទួលការធានា នៅពេលនិងចំពោះទំហំដែល បានបាត់បង់នេះ មិនអាចទូទាត់បានដោយមូលនិធិទុកចិត្តលើភាពធានា ( Sponsorship Trust Fund ) ដែលយោងទៅរកមាត្រា ២ នៃឧបសម្ព័ន្ធនេះ តាមសមាមាត្រដែលចំនួនទទួលខុស ត្រូវមិនបានគ្រោងទុក សរុបអតិបរិមា ក្រោមការធានាចំពោះការវិនិយោគ ដែលមានអ្នកធានា ដោយភាគហ៊ុនរបស់ខ្លួន ចំពោះចំនួនទាំងអស់នៃការទទួលខុសត្រូវមិនបានគ្រោងទុក ក្រោមកិច្ចធានាចំពោះការវិនិយោគ ដែលមានអ្នកធានាដោយសមាជិកទាំងអស់ ។

គ-នៅក្នុងការសំរេចចិត្តរបស់ខ្លួន ក្នុងការចេញកិច្ចធានានៅក្រោមឧបសម្ព័ន្ធនេះ ទីភ្នាក់ងារនឹងសងបំណុល ក្នុងការសង្ឃឹមថា សមាជិកដែលធានា នឹងត្រៀមប្រឈមនឹងកាតព្វកិច្ចក្រោមឧបសម្ព័ន្ធនេះហើយនឹងផ្តល់អាទិភាពចំពោះការវិនិយោគដែលត្រូវបានធានារួមដោយបណ្តាប្រទេសម្ចាស់ផ្ទះដែលពាក់ព័ន្ធ ។

ឃ-ទីភ្នាក់ងារនឹងពិគ្រោះជាមួយនឹងសមាជិកដែលធានាយូរៗ ម្តងចំពោះប្រតិបត្តិការរបស់ខ្លួនក្រោមឧបសម្ព័ន្ធនេះ ។

មាត្រា ២ - មូលនិធិទុកចិត្តលើភាពធាន ( Sponsorship Trust Fund )

ក- ប្រាក់រង្វាន់ និងប្រាក់ចំណូលផ្សេងៗ ដែលអាចពន្យល់ពីប្រភពបាន ចំពោះកិច្ចធានាការវិនិយោគ ដែលមានអ្នកធានា គិតទាំងការបង្វិលមកឱ្យការវិនិយោគនូវប្រាក់រង្វាន់ និងប្រាក់ចំណូល នឹងត្រូវកាន់កាប់នៅក្នុងគណនីដោយឡែក ដែលនឹងត្រូវហៅថា មូលនិធិទុកចិត្តលើភាពធានា ។

ខ-រាល់ចំណាយរដ្ឋបាល និងការបង់ប្រាក់ចំពោះការទាមទារ ដែលអាចពន្យល់ពីមូលហេតុបាន ចំពោះកិច្ចធានាដែលចេញក្រោមឧបសម្ព័ន្ធនេះ នឹងត្រូវបង់ចេញពី មូលនិធិទុកចិត្តលើភាពធានា ។

គ- ទ្រព្យសម្បត្តិ និងមូលនិធិទុកចិត្តលើភាពធានា នឹងត្រូវបានកាន់កាប់និងគ្រប់គ្រងសំរាប់គណនីរួម នៃប្រទេសអ្នកធានា ហើយនឹងត្រូវបានរក្សាទុកដោយឡែក និងដាច់ពីគ្នា ពីទ្រព្យសម្បត្តិរបស់ទីភ្នាក់ងារ ។

<u>មាត្រា ៣</u> :-ការកោះហៅឱ្យបង់ប្រាក់ពីសមាជិកដែលធានា ( Calls on Sponsoring Members )

ក-ចំពោះទំហំដែលចំនួនណាមួយអាចបង់បាន ដោយទីភ្នាក់ងារចំពោះការបាត់បង់ក្រោមកិច្ចធានាដែលត្រូវបានធានាហើយចំនួននេះមិនអាចបង់ចេញបានពីទ្រព្យសម្បត្តិរបស់មូលនិធិទុកចិត្តលើភាពធានា ទីភ្នាក់នឹងកោះហៅសមាជិកដែលធានានីមួយៗឱ្យបង់ចូលមូលនិធិនេះនូវចំណែកនៃចំនួននេះ ដែលនឹងកំណត់សំរបជាមួយផ្នែក(ខ) នៃមាត្រា១ ក្នុងឧបសម្ព័ន្ធនេះ ។

ខ-គ្មានសមាជិកណាដែលនឹងទទួលខុសត្រូវ បង់ប្រាក់ចំនួនណាមួយ តាមការកោះហៅ ~~តាមបញ្ញត្តិនៃមាត្រានេះ ប្រសិនបើចំនួនបង់ប្រាក់សរុប ដែលបានធ្វើដោយសមាជិកនោះលើស~~ ពីចំនួនសរុបនៃការធានាទូទាត់សងការវិនិយោគ ដែលមានអ្នកធានា ដោយសមាជិកនោះ ។

គ-ឈលើការផុតកំណត់នៃកិច្ចធានាទូទាត់សងការវិនិយោគដែលមានអ្នកធានាដោយមាជិកមួយ ការទទួលខុសត្រូវរបស់សមាជិកនេះ នឹងត្រូវបន្ថយដោយចំនួនមួយសមមូលទៅនឹងចំនួននៃកិច្ចធានានោះ ការទទួលខុសត្រូវនោះ នឹងត្រូវបានបន្ថយផងដែរ លើមូលដ្ឋានសមាមាត្រនឹងភាគហ៊ុននីមួយៗពីលើការបង់ដោយទីភ្នាក់ងារ ចំពោះការទាមទារណាមួយ ទាក់ទងទៅនឹងការវិនិយោគ ដែលមានអ្នកធានា ហើយនឹងក្រៅពីនេះ នឹងបន្តប្រសិទ្ធិភាពរហូតដល់ផុតកំណត់នូវរាល់កិច្ចធានា · ចំពោះវិនិយោគដែលមានអ្នកធានាដែលមិនទាន់បានសងនៅពេលដែលត្រូវបង់ឱ្យនោះ ។

ឃ-ប្រសិនបើសមាជិកអ្នកធានា មិនអាចទទួលខុសត្រូវចំពោះចំនួនដែលសុំឱ្យបង់តាមបញ្ញត្តិក្នុងមាត្រានេះ ដោយសារតែការកំរិតដែលមាននៅក្នុងផ្នែក (ខ) និង (គ)ខាងលើ ឬប្រសិនបើសមាជិកអ្នកធានាណាមួយ នឹងមិនប្រកាន់តាមកិច្ចសន្យារបស់ខ្លួនក្នុងការបង់ប្រាក់ នូវចំនួនមិនទាន់សង ឆ្លើយតាមការសុំឱ្យបង់នោះទេ ការទទួលខុសត្រូវក្នុងការបង់ប្រាក់នូវចំនួននោះ នឹងត្រូវបែងចែកតាមសមាមាត្រនៃភាគហ៊ុននីមួយៗ ដោយសមាជិកអ្នកធានាដទៃទៀត ។ ភាពទទួលខុសត្រូវរបស់សមាជិកស្របតាមផ្នែកនេះ នឹងទៅជាកម្មវត្ថុក្នុងការកំរិតព្រំដែន កំណត់ជាមុននៅក្នុងផ្នែក(ខ) និង (គ) ខាងលើ ។

ង-ការបង់ប្រាក់ណាមួយ របស់សមាជិកអ្នកធានា អនុលោមតាមការសុំឱ្យបង់ប្រាក់ស្របទៅនឹងមាត្រានេះនឹងត្រូវធ្វើភ្លាមៗ និងជារូបិយប័ណ្ណដែលអាចប្រើប្រាស់បានដោយសេរី ។

មាត្រា ៤- ការវាយតម្លៃបិយវត្ថុ និងការសងប្រាក់វិញ ( Refund )

ខកំណត់ក្នុងការវាយតម្លៃបិយវត្ថុ និងការសងប្រាក់វិញដែលមានក្នុងអនុសញ្ញានេះ ចំពោះដើមទុនបរិវិសកម្ម នឹងត្រូវបានអនុវត្ត mutatis mutandis ចំពោះមូលនិធិដែលបង់ប្រាក់ ដោយសមាជិក ដោយសារការវិនិយោគដែលមានអ្នកធានា ។

មាត្រា ៥- ការរ៉ាប់រងជាថ្មី ( Reinsurance )

ក- តាមលក្ខខណ្ឌដែលបានចែងក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ ទីភ្នាក់ងារអាច ផ្តល់ការរ៉ាប់រងជាថ្មី ចំពោះសមាជិកមួយ ទីភ្នាក់ងារដែលពាក់ព័ន្ធមួយ ទីភ្នាក់ងារតំបន់មួយ ដូចដែលបានកំណត់ក្នុងផ្នែក(ក)នៃមាត្រា២០ នៃអនុសញ្ញានេះ ឬចំពោះអ្នករ៉ាប់រងឯកជនមួយ នៅក្នុងប្រទេសសមាជិកមួយ ។ ខ កំណត់នៃឧបសម្ព័ន្ធនេះដែលពាក់ព័ន្ធនឹងការធានា ហើយ ~~នឹងនៃមាត្រា២០ និង ២១ នៃអនុសញ្ញានេះ នឹងត្រូវអនុវត្ត (mutatis mutandis) ចំពោះ~~ ការរ៉ាប់រងជាថ្មី ដែលចែងនៅក្នុងផ្នែកនេះ ។

ខ- ទីភ្នាក់ងារអាចទទួលរ៉ាប់រងជាថ្មី ចំពោះការវិនិយោគដែលបានធានា ដោយទីភ្នាក់ងារតាមឧបសម្ព័ន្ធនេះ ហើយនឹងទទួលថ្លៃរ៉ាប់រងជាថ្មីនេះពីមូលនិធិទុកចិត្តលើភាពធានា ។ គណៈកម្មការ នឹងសំរេចអំពីព្រំដែននៃការបាត់បង់ បែងចែកកាតព្វកិច្ចនៃសមាជិកដែលធានា យោងទៅផ្នែក(ខ) នៃមាត្រា១នៃឧបសម្ព័ន្ធនេះ អាចនឹងបន្ថយដោយសារការទូទាត់ ការរ៉ាប់រងជាថ្មីដែលបានទទួល ។

មាត្រា ៦- គោលការណ៍ប្រតិបត្តិការ

ដោយមិនធ្វើឱ្យខូចខាតដល់ ខ កំណត់នៃឧបសម្ព័ន្ធនេះ ខ កំណត់ទាំងឡាយចំពោះ ប្រតិបត្តិការធានាតាមជំពូក III នៃអនុសញ្ញានេះ និងចំពោះការគ្រប់គ្រងហិរញ្ញវត្ថុតាមជំពូកV នៃអនុសញ្ញានេះ នឹងត្រូវអនុវត្ត mutatis mutandis ចំពោះការធានាការវិនិយោគដែលមានអ្នក ធានា លើកលែងតែ(១) ការវិនិយោគនោះមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ភាពធានា ប្រសិន បើបានធ្វើនៅក្នុងទឹកដីនៃសមាជិកណាមួយ និងជាពិសេសនៃសមាជិកកំពុងអភិវឌ្ឍន៍ណាមួយ ដោយវិនិយោជិកម្នាក់ ឬច្រើននាក់ ដែលសមស្របតាមផ្នែក(ក)នៃមាត្រា១នៃឧបសម្ព័ន្ធនេះ និង(២)ទីភ្នាក់ងារមិនអាចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន សំរាប់ការធានាណា មួយឬរ៉ាប់រងជាថ្មី ដែលចែងនៅក្នុងឧបសម្ព័ន្ធនេះ ហើយកិច្ចសន្យានៃការធានា ឬ រ៉ាប់រងជាថ្មី នីមួយៗ បង្កើយតាមឧបសម្ព័ន្ធនេះ និងផ្តល់យ៉ាងច្បាស់លាស់ ។

## មាត្រា ៨- ការបោះឆ្នោត ( Voting )

សំរាប់ការសំរេចចិត្តដែលទាក់ទងទៅនឹង ការវិនិយោគដែលមានអ្នកធានាសមាជិកអ្នកធានានីមួយៗ នឹងទទួលបានសំឡេងបន្ថែមមួយសំរាប់ ១០.០០០ Special Drawing Rigtits នីមួយៗ ដែលសមមូល និងចំនួនដែលបានធានា ឬរ៉ាប់រងជាថ្មី នៅលើមូលដ្ឋាននៃភាពធានារបស់ខ្លួន ហើយសមាជិកម្ចាស់ផ្ទះនៃការវិនិយោគ ដែលមានអ្នកធានានីមួយៗ នឹងបានទទួលសំឡេងបន្ថែមមួយ សំរាប់ ១០.០០០ Special Drawing Rigtits នីមួយៗ ដែលសមមូលទៅនឹងចំនួនដែលបានធានា និងរ៉ាប់រងជាថ្មី ចំពោះការវិនិយោគដែលមានអ្នកធានា ដែលបានទទួលដោយសមាជិកម្ចាស់ផ្ទះ ។ សំឡេងបន្ថែមនេះ នឹងត្រូវបានបោះ តែសំរាប់ការសំរេចចិត្តដែលទាក់ទងទៅនឹងការវិនិយោគដែលមានអ្នកធានា ហើយក្រៅពីនេះ នឹងមិនត្រូវបានទទួលស្គាល់ ក្នុងការកំណត់អំណាចបោះឆ្នោតនៃសមាជិក ។

## ឧបសម្ព័ន្ធទី២

## ការដោះស្រាយជំលោះ រវាងសមាជិកមួយ និងទីភ្នាក់ ក្រោមមាត្រា ៥៧

<u>មាត្រា ១-</u> ការអនុវត្តន៍ឧបសម្ព័ន្ធ

រាល់ជំលោះនៅក្នុងព្រំដែននៃមាត្រា ៥៧ នៃអនុសញ្ញានេះ នឹងត្រូវបានដោះស្រាយ អនុលោមទៅតាមវិធី ដែលចែងនៅក្នុងឧបសម្ព័ន្ធនេះ លើកលែងតែក្នុងករណីដែលទីភ្នាក់ងារបានឈានដល់ការព្រមព្រៀងជាមួយសមាជិក ស្របតាមផ្នែក(១)(២)នៃមាត្រា ៥៧ ។

<u>មាត្រា ២-</u> ការព្រមព្រៀង ( Negotiation )

ភាគីជំលោះនៅក្នុងព្រំដែននៃឧបសម្ព័ន្ធនេះ នឹងព្យាយាមដោះស្រាយជំលោះនេះ ដោយសារការព្រមព្រៀងមុននឹងស្វែងរកការសំរុះសំរួល ឬការកាត់សេចក្តីដោយតុលាការ ។ ការព្រមព្រៀង នឹងចាត់ទុកថាត្រូវផុតកំណត់ប្រសិនបើភាគីជំលោះមិនអាចឈានដល់ដំណោះស្រាយក្នុងរយៈពេលមួយរយម្ភៃថ្ងៃ ចាប់ពីថ្ងៃដែលស្នើសុំឱ្យមានការព្រមព្រៀង ។

<u>មាត្រា ៣-</u> ការសំរុះសំរួល ( Consiliation )

ក- ប្រសិនបើជំលោះមិនអាចដោះស្រាយដោយការព្រមព្រៀង ភាគីណាមួយអាចស្នើទៅរកការកាត់សេចក្តីដោយតុលាការ អនុលោមតាម ខ កំណត់នៃមាត្រា ៤ នៃឧបសម្ព័ន្ធនេះ លើកលែងតែភាគីទាំងអស់ដោយការយល់ព្រមទៅវិញទៅមកបានសំរេចចិត្តបែរ ទៅរកវិធីសំរុះសំរួលជាមុនដែលបានកំណត់ក្នុងមាត្រានេះ ។

ខ- ការយល់ព្រមដើម្បីរកការសំរុះសំរួល នឹងបញ្ជាក់រឿងរ៉ាវក្នុងជំលោះការទាមទារនៃភាគី និងប្រសិនបើអាចប្រើជាប្រយោជន៍បាន ត្រូវបញ្ជាក់ឈ្មោះអ្នកសំរុះសំរួលយល់ព្រមដោយភាគី ។ ក្នុងករណីដែលគ្មានការយល់ព្រមលើអ្នកសំរុះសំរួល ភាគីអាចរួមគ្នាស្នើសុំឬមួយអគ្គលេខាធិការនៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយជំលោះនៃការវិនិយោគ (ពេលនេះនឹងជាបន្តនឹងហៅថា ICSID)ឬប្រធាននៃតុលាការអន្តរជាតិ ដើម្បីតែងតាំងអ្នកសំរុះសំរួល។ ដំណើរការសំរុះសំរួលនឹងត្រូវបញ្ចប់ប្រសិនបើអ្នកសំរុះសំរួលមិនត្រូវបានតែងតាំងក្នុងរយៈពេលកៅសិបថ្ងៃ បន្ទាប់ពីការយល់ព្រមងាកទៅរកការសំរុះសំរួល ។

គ- លើកលែងតែត្រូវបានកំណត់ផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនេះ ដែលបានយល់ព្រមពីភាគី អ្នកសំរុះសំរួលនឹងកំណត់ពីច្បាប់ ដើម្បីដឹកនាំដំណើរការសំរុះសំរួលដែលត្រូវណែ-

នាំដោយច្បាប់សំរុះសំរួល អនុលោមតាមអនុសញ្ញា អំពីការដោះស្រាយជំលោះវិនិយោគរវាងរដ្ឋ និងជាតិនៃរដ្ឋផ្សេងទៀត ។

ឃ- ភាគីទាំងឡាយ នឹងសហការដោយស្មោះត្រង់ ជាមួយនឹងអ្នកសំរុះសំរួល ហើយ នឹងជាពិសេស ផ្តល់ដល់អ្នកសំរុះសំរួលរាល់ពត៌មាន និងឯកសារដែលអាចជួយគាត់ក្នុងការបំ-ពេញមុខងារ គេត្រូវផ្តល់នូវការពិចារណាយ៉ាងហ្មត់ចត់ចំពោះការណែនាំរបស់គាត់ ។

ង- លើកលែងតែត្រូវបានយល់ព្រមផ្សេងទៀតដោយភាគីទាំងឡាយ ក្នុងរយៈពេលមិន លើសពីមួយរយប៉ែតសិបថ្ងៃ គិតចាប់ពីថ្ងៃដែលបានតែងតាំង អ្នកសំរុះសំរួលត្រូវប្រគល់ជូនទៅ ភាគីទាំងឡាយ នូវរបាយការណ៍ដែលកត់ត្រាពីលទ្ធផលនៃការប្រឹងប្រែងរបស់ខ្លួន និងការផ្តើម ចេញនៃទំនាស់រវាងភាគីទាំងឡាយ និងសំណើរបស់ខ្លួនដើម្បីដោះស្រាយ ។

ច- ក្នុងរវាងហុកសិបថ្ងៃ ចាប់ពីថ្ងៃទទួលរបាយការណ៍ ភាគីនីមួយ ៗ នឹងបញ្ជាក់ជា លាយលក្ខណ៍អក្សរ នូវទស្សនៈរបស់ខ្លួនចំពោះរបាយការណ៍ ជូនទៅភាគីម្ខាងទៀត ។

ឆ- គ្មានភាគីណាមួយនៃដំណើរការសំរុះសំរួល នឹងត្រូវបានប្រគល់សិទ្ធិឱ្យស្វែងរកការ សំរេចក្តីដោយតុលាការ លើកលែងតែ ៖

១- អ្នកសំរុះសំរួលមិនអាចប្រគល់ជូនរបាយការណ៍របស់ខ្លួន ក្នុងរយៈពេលដែលកំណត់ ក្នុងផ្នែក (ង) ខាងលើ ឬ

២- ភាគីទាំងឡាយមិនអាចទទួលយកនូវសំណើទាំងអស់ ដែលមានក្នុងរបាយការណ៍ ក្នុងរវាងហុកសិបថ្ងៃបន្ទាប់ពីបានទទួលវា ឬ

៣- ភាគីទាំងឡាយ បន្ទាប់ពីបានផ្លាស់ប្តូរទស្សនៈអំពីរបាយការណ៍ត្រូវបរាជ័យក្នុងការ យល់ព្រមចំពោះដំណោះស្រាយនៃរាល់បញ្ហាទំនាស់ ក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពីបានទទួលរបាយការណ៍របស់អ្នកសំរុះសំរួល ឬ

៤- ភាគីមួយមិនអាចបញ្ជាក់ទស្សនៈ អំពីរបាយការណ៍ ដូចបានកំណត់ក្នុងផ្នែក (ច) ខាងលើ

ជ- លើកលែងតែភាគីទាំងឡាយយល់ព្រមផ្សេងពីនេះ ថ្លៃឈ្នួលសំរាប់អ្នកសំរុះសំរួល នឹងត្រូវកំណត់ នៅលើមូលដ្ឋាននៃអត្រាដែលអាចអនុវត្តបានចំពោះ ការសំរុះសំរួលរបស់ (ICSID) ។ ថ្លៃឈ្នួលនេះ និងតម្លៃផ្សេងទៀតសំរាប់ដំណើរការសំរុះសំរួល នឹងត្រូវរ៉ាប់រងស្មើ គ្នាដោយភាគី ទាំងឡាយ ។ ភាគីនីមួយៗ នឹងសងថ្លៃដោយចំណាយផ្ទាល់របស់ខ្លួន ។

<u>មាត្រា ៤-</u> ការកាត់សេចក្តីដោយតុលាការ (Arbitration)

ក- ដំណើរការកាត់ក្តីនឹងត្រូវបានចាត់តាំងឡើងដោយសេចក្តីប្រកាសរបស់ភាគីដែល

ស្វែងរកការកាត់សេចក្តី (អ្នកដើមចោទ) ចំពោះភាគីម្ខាងទៀត ឬភាគីទាំងឡាយនៃជំលោះ (ចុងចម្លើយ) ។ សេចក្តីប្រកាសនឹងបញ្ជាក់ពីធម្មជាតិនៃជំលោះ ការស្វែងរកដំណោះស្រាយ និងឈ្មោះអ្នកកាត់ក្តី ដែលចង្អុលប្រាប់ដោយដើមចោទ ។ ក្នុងរវាងសាមសិបថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីប្រកាសចុងចម្លើយ នឹងបញ្ជាក់ទៅដើមចោទ អំពីឈ្មោះអ្នកកាត់ក្តីដែលចង្អុលប្រាប់ដោយចុងចម្លើយ ។ ភាគីទាំងពីរ ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីថ្ងៃតែងតាំងអ្នកកាត់ក្តីទីពីរ ជ្រើសរើសអ្នកកាត់ក្តីទីបីម្នាក់ទៀត ដែលនឹងធ្វើជាប្រធាន នៃតុលាការកាត់ក្តី ( Arbitrat Tribunal ) ។

ខ- ប្រសិនបើតុលាការ ( Tribunal )មិនត្រូវបានបង្កើតឡើង ក្នុងរវាងហុកសិបថ្ងៃ ចាប់ពីថ្ងៃប្រកាស អ្នកកាត់ក្តីមិនទាន់បានតែងតាំង ឬប្រធានមិនទាន់បានជ្រើសរើសតាមសំណើរបស់ភាគីទាំងឡាយ ដោយអគ្គលេខាធិការ នៃ ICSID ។ ប្រសិនបើគ្មានសំណើរនេះទេ ឬប្រសិនបើអគ្គលេខាធិការមិនអាចធ្វើការ ក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីមានសំណើភាគីណាមួយក៏ដោយអាចស្នើប្រធានតុលាការអន្តរជាតិឱ្យធ្វើការតែងតាំង ។

គ- មិនមានភាគីណាមួយមានសិទ្ធិផ្លាស់ប្តូរអ្នកកាត់សេចក្តីដែលតែងតាំងដោយខ្លួនឯងភ្លាម ពេលដែលឮថាជំលោះចាប់ផ្តើមទេ ។ ក្នុងករណីដែលអ្នកកាត់ក្តីណាម្នាក់ ( គិតទាំងប្រធានតុលាការផង )លាលែង ស្លាប់ ឬទៅជាអសមត្ថភាព អ្នកបន្តតំណែងនឹងត្រូវតែងតាំងតាមរបៀបដែលបានធ្វើចំពោះអ្នកមុន ហើយអ្នកបន្តតំណែងនេះនឹងទទួលអំណាច និងករណីកិច្ចដូចគ្នា និងអ្នកកាត់ក្តី ដែលខ្លួនចូលបន្ត ។

ឃ- តុលាការនឹងកោះប្រជុំជាលើកដំបូងនៅពេល និងទីកន្លែងដែលនឹងត្រូវបានកំណត់ដោយប្រធាន ។ ជាបន្តទៀត តុលាការ នឹងកំណត់ទីកន្លែង និងកាលបរិច្ឆេទនៃការប្រជុំរបស់ខ្លួន ។

ង- លើកលែងតែបានកំណត់ផ្សេងទៀតក្នុងឧបសម្ព័ន្ធនេះ ឬដែលបានយល់ព្រមដោយភាគីទាំងឡាយ តុលាការនឹងកំណត់អំពីវិធីប្រព្រឹត្តិរបស់ខ្លួន ហើយនឹងត្រូវបានណែនាំដោយច្បាប់កាត់សេចក្តីអនុលោមតាមអនុសញ្ញាស្តីពីការដោះស្រាយជំលោះវិនិយោគរវាង រដ្ឋ និងជាតិ នៃរដ្ឋផ្សេងទៀត ។

ច- តុលាការនឹងជាចៅក្រមនៃសមត្ថកិច្ចរបស់ខ្លួនលើកលែងតែ ប្រសិនបើមានការមិនយល់ស្របមួយបានលើកឡើងចំពោះតុលាការ ដើម្បីឱ្យជំលោះនេះចូលទៅក្នុងយុត្តាធិការរបស់គណៈកម្មការ ឬក្រុមប្រឹក្សាតាមមាត្រា ៥៦ ឬក្នុងយុត្តាធិការរបស់អង្គការច្បាប់ ឬអង្គការតុលាការដែលតែងតាំងតាមការយល់ស្របនៅក្នុងមាត្រា ១ នៃឧបសម្ព័ន្ធនេះ ហើយតុលាការ

ក៏ពេញចិត្ត ថាការជំទាស់នេះជាការពិតប្រាកដ ការជំទាស់នេះ នឹងបញ្ជូនទៅគណៈកម្មការ ឬក្រុមប្រឹក្សា ឬអង្គការដែលបានចាត់តាំង ហើយរឿងក្តីនេះអាចត្រូវនៅរង់ចាំរហូតឈានទៅដល់ការ សំរេចចិត្តចំពោះបញ្ហានេះ ដែលនឹងអាចចាត់ទុកជាមោឃៈដោយតុលាការ ។

ង- ជំលោះណាមួយដែលស្ថិតនៅក្នុងរង្វង់ឧបសម្ព័ន្ធនេះ តុលាការនឹងអនុវត្ត ខកំណត់នៃអនុសញ្ញា ការយល់ព្រមរវាងភាគីទាំងឡាយចំពោះជំលោះច្បាប់ និងបទបញ្ញារបស់ទីភ្នាក់ងារច្បាប់អន្តរជាតិ ដែលអាចអនុវត្តបាន ច្បាប់ក្នុងប្រទេសសមាជិកដែលពាក់ព័ន្ធ ក៏ដូចជា ខដែលបានចែងក្នុងកិច្ចសន្យាវិនិយោគ ដែលអាចអនុវត្តបាន ប្រសិនបើមានមួយណា ។ ដោយមិនឱ្យធ្វើខូចខាតចំពោះ ខ ដែលបានចែងក្នុងអនុសញ្ញានេះ តុលាការអាចសំរេចជំលោះ ex-aquo et bono ប្រសិនបើទីភ្នាក់ងារ និងសមាជិកពាក់ព័ន្ធយល់ព្រម ។ តុលាការអាចមិនរក non liquet ទៅលើភាពស្ងប់ស្ងាត់ និងភាពងងឹត នៃច្បាប់ ។

ច- តុលាការនឹងស្តាប់ដោយយោងឈ្មោះត្រង់ពីគ្រប់ភាគីទាំងអស់ ។ រាល់សេចក្តីសំរេចចិត្តរបស់តុលាការ នឹងត្រូវយកតាមសម្លេងភាគច្រើន ហើយនឹងបញ្ជាក់ពីហេតុផល ដែលគេបានសំអាង ។ សាលក្រម ( Award )តុលាការនឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយនឹងត្រូវចុះហត្ថលេខាដោយអ្នកកាត់ក្តីយ៉ាងហោចណាស់ពីរនាក់ ហើយច្បាប់ចម្លងមួយ ច្បាប់នឹងត្រូវផ្ញើជូនចំពោះភាគីនីមួយៗ ។ សាលក្រម គឺជាការសំរេចចុងក្រោយ និងមិនអាចចាត់ទុកជាមោឃៈលើភាគីទាំងអស់ ហើយមិនត្រូវជាកម្មវត្ថុសំរាប់ឧទ្ធរណ៍ មោឃៈកម្ម ឬកែប្រែ ។

ឈ-ប្រសិនបើជំលោះណាមួយកើតឡើងរវាងភាគីចំពោះអត្ថន័យ ឬព្រំដែននៃសាល-ក្រម ក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពីសាលក្រមត្រូវបានប្រគល់ជូន ភាគីណាមួយអាចស្នើសុំឱ្យធ្វើការបកស្រាយសាលក្រម ដោយលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ ចំពោះប្រធានតុលា-ការដែលចេញសាលក្រម ។ ប្រសិនបើអាចធ្វើបាន ប្រធានតុលាការ នឹងប្រគល់សំណើនេះជូនទៅតុលាការដែលចេញសាលក្រម ហើយនឹងបើកប្រជុំតុលាការក្នុងរយៈពេលហុកសិបថ្ងៃបន្ទាប់ពីការទទួលពាក្យស្នើសុំ ។ ប្រសិនបើគ្មានលទ្ធភាព តុលាការថ្មីនឹងត្រូវបានតែងតាំងអនុលោមតាម ខ ដែលបានចែងនៅក្នុងផ្នែក(ក)ដល់(ឃ)ខាងលើ ។ តុលាការអាចរក្សាអំណាចនៃសាលក្រម ដោយព្យួរទុកការសំសេចចិត្តអំពីសំណើសុំបកស្រាយសាលក្រមនេះ ។

ញ- សមាជិកនីមួយៗ នឹងទទួលស្គាល់សាលក្រម ដែលបានប្រគល់ជូនតាមមាត្រានេះថាមិនអាចចាត់ទុកជាមោឃៈបាន និងអាចបង្ខំបាននៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើថាជាការវិនិច្ឆ័យ ចុងក្រោយរបស់តុលាការនៅក្នុងសមាជិកនោះ ។ ការធ្វើឱ្យសំរេចតាមសាលក្រមនឹងត្រូវ គ្រប់គ្រងដោយច្បាប់ដែលទាក់ទងទៅនឹងការធ្វើឱ្យសំរេចការវិនិច្ឆ័យដោយបង្ខំនៅក្នុងរដ្ឋដែលទឹកដីរបស់ខ្លួនត្រូវបានធ្វើការអនុវត្តន ហើយនឹងមិនត្រូវបន្ទរបន្ថយពីច្បាប់ដោយបង្ខំដែល

ទាក់ទងទៅនឹងការរួចផុតពីការធ្វើឱ្យសំរេចនេះ ។

៥- លើកលែងតែភាគីទាំងអស់បានយល់ស្របផ្សេងពីនេះ ប្រាក់ឈ្នួល និងប្រាក់រង្វាន់ ដែលត្រូវបង់ជូនអ្នកកាត់ក្តី នឹងត្រូវកំណត់ទៅលើមូលដ្ឋាន នៃអត្រាដែលអាចអនុវត្តបានចំពោះការកាត់សេចក្តីរបស់ ICSID ។ ភាគីនីមួយៗ ត្រូវសងថ្លៃតម្លៃចាយវាយផ្ទាល់របស់ខ្លួន ឬរួមជាមួយការចាយវាយសំរាប់ដំណើរការកាត់ក្តី ។ តម្លៃនៃតុលាការត្រូវទទួលចេញដោយភាគីទាំងឡាយ ក្នុងសមាមាត្រស្មើគ្នា លើកលែងតែតុលាការសំរេចផ្សេងពីនេះ ។ បញ្ហាណាដែលទាក់ទងនឹងការបែងចែកតម្លៃតុលាការ ឬវិធីចាត់ការដើម្បីបង់ប្រាក់តាមតម្លៃនោះនឹងត្រូវសំរេចដោយតុលាការ ។

<u>មាត្រា ៥-</u> Service of Process

Service of any notice or process ដែលទាក់ទងទៅនឹងការប្តឹងណាមួយក្នុងឧបសម្ព័ន្ធនេះ នឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ វាត្រូវធ្វើដោយទីភ្នាក់ងារតាមការផ្តល់អំណាចឱ្យ ដោយសមាជិកពាក់ព័ន្ធអនុលោមតាមមាត្រា ៣៨ នៃអនុសញ្ញានេះ និងដោយសមាជិកនោះ នៅការិយាល័យធំរបស់ទីភ្នាក់ងារ ។

## តារាង ក ( Schednle A )

## សមាជិកភាព និងបរិវិសកម្ម

## ( Membership and Subscriptions )

| ប្រទេស | ប្រភេទទីមួយ ចំនួនភាគហ៊ុន | បរិវិសកម្ម ( លាន sor ) |
|---|---|---|
| អូស្ត្រាលី | ១.៨១៣ | ១៨.១៣ |
| អូទ្រីស | ៨៨៥ | ៨.៨៥ |
| បែលហ្ស៊ិក | ៦.០៣០ | ៦០.៣០ |
| កាណាដា | ៦.៩៦៥ | ៦៩.៦៥ |
| ដាណឺម៉ាក | ៨១៨ | ៨.១៨ |
| ហ្វាំងឡង់ | ៦០០ | ៦.០០ |
| បារាំង | ៤.៨៦០ | ៤៨.៦០ |
| អាល្លឺម៉ង់-សាធារណរដ្ឋសហព័ន្ធ | ៥.០៨១ | ៥០.៨១ |
| អ៊ីស្លង់ | ៩០ | ០.៩០ |
| អៀរឡង់ | ៣៦៩ | ៣.៦៩ |
| អ៊ីតាលី | ២.៨២០ | ២៨.២០ |
| ជប៉ុន | ៥.០៩៥ | ៥០.៩៥ |
| លុចសំបួរ | ១១៦ | ១.១៦ |
| ហុល្លង់ | ២.១៦៩ | ២១.៦៩ |
| នូវែលហ្សេឡង់ | ៥១៣ | ៥.១៣ |
| ណរវែល | ៦៩៩ | ៦.៩៩ |
| អាហ្វ្រិកខាងត្បូង | ៩៤៣ | ៩.៤៣ |
| ស៊ុយអែត | ១.០៤៩ | ១០.៤៩ |
| ស្វ៊ីស | ១.៥០០ | ១៥.០០ |
| រាជាណាចក្រួម | ៤.៨៦០ | ៤៨.៦០ |
| សហរដ្ឋ | ២០.៥១៩ | ២០៥.១៩ |
| | ៥៩.៤៨៣ | ៥៩៤.៨៣ |

| ប្រទេស | ប្រភេទទីពីរ ចំនួនភាគហ៊ុន | បរិវិសកម្ម (លានSDR) |
| --- | --- | --- |
| អាហ្វកានីស្ថាន | ១១៨ | ១.១៨ |
| អាល់ហ្សេរី | ៦៤៩ | ៦.៤៩ |
| អង់ទីហ្គ និងបាប៊ូដា | ៥០ | ០.៥០ |
| អាហ្សង់ទីន | ១.៦៥៤ | ១៦.៥៤ |
| បាហាម៉ា | ១០០ | ១.០០ |
| បារ៉ែន | ៧៧ | ០.៧៧ |
| បង់ក្លាដែស | ៣៤០ | ៣.៤០ |
| បានបាដូស | ៦៨ | ០.៦៨ |
| បេលីស | ៥០ | ០.៥០ |
| បេណាំង | ៦១ | ០.៦១ |
| ប៊ូតាន | ៥០ | ០.៥០ |
| បូលីវី | ១៦៥ | ១.៦៥ |
| បុតស្វាណា | ៥០ | ០.៥០ |
| ប្រេស៊ីល | ១.៤៧៩ | ១៤.៧៩ |
| បួគីណាហ្វាសូ | ៦១ | ០.៦០ |
| ភូមា | ១៧៨ | ១.៧៨ |
| ប៊ូរុនឌិ | ៧៤ | ០.៧៤ |
| កាមេរូន | ១០៧ | ១.០៧ |
| កាបវែរ | ៥០ | ០.៥០ |
| សាធារណរដ្ឋអាហ្វ្រិកកណ្ដាល | ៦០ | ០.៦០ |
| ឆាដ | ៦០ | ០.៦០ |
| ស៊ីលី | ៤៨៥ | ៤.៨៥ |
| ចិន | ៣.១៣៨ | ៣១.៣៨ |
| កូឡុំប៊ី | ៤៣៧ | ៤.៣៧ |
| កូម៉ូរ៉ុស | ៥០ | ០.៥០ |
| កុងហ្គោ-សាធារណរដ្ឋប្រជាមានិត | ៦៥ | ០.៦៥ |

ប្រទេសដែលមានចុះបញ្ជីនៅក្នុងប្រភេទទីពីរជាប្រទេសសមាជិកកំពុងអភិវឌ្ឍន៍ ក្នុងគោលបំណង នៃអនុសញ្ញានេះ ។

| ប្រទេស | ប្រភេទទីពីរ ចំនួនភាគហ៊ុន | បរិវិសកម្ម ( លានSDR ) |
|---|---|---|
| ~~កូស្តារីកា~~ | ~~១១៧~~ | ~~១.១៧~~ |
| ស៊ីព្រ | ១០៤ | ១.០៤ |
| ជីប៊ូទី | ៥០ | ០.៥០ |
| ដូមីនិកា | ៥០ | ០.៥០ |
| ~~សាធារណរដ្ឋដូមីនិកាំង~~ | ~~១៤៧~~ | ~~១.៤៧~~ |
| អេក្វាដ័រ | ១៨២ | ១.៨២ |
| អេហ្ស៊ីប-សាធារណរដ្ឋអារ៉ាប់ | ៤៥៩ | ៤.៥៩ |
| អែលសាល់វ៉ាដ័រ | ១២២ | ១.២២ |
| ហ្គីណេអេក្វាទ័រ | ៥០ | ០.៥០ |
| អេត្យូពី | ៧០ | ០.៧០ |
| ហ្វីជី | ៧១ | ០.៧១ |
| ហ្គាបុង | ៩៦ | ០.៩៦ |
| ហ្គំប៊ី | ៥០ | ០.៥០ |
| ហ្គាណា | ២៤៥ | ២.៤៥ |
| ក្រិន | ២៨០ | ២.៨០ |
| ហ្គ្រើណាដា | ៥០ | ០.៥០ |
| ក្វាតេម៉ាឡា | ១៤០ | ១.៤០ |
| ហ្គីណេ | ៩១ | ០.៩១ |
| ហ្គីណេប៊ីសាវ | ៥០ | ០.៥០ |
| ហ្គីយ៉ាន | ៨៤ | ០.៨៤ |
| ហៃទី | ៧៥ | ០.៧៥ |
| ហុងឌូរ៉ាស់ | ១០១ | ១.០១ |
| ហុងគ្រី | ៥៦៤ | ៥.៦៤ |

| | | |
|---|---|---|
| ឥណ្ឌា | ៣.០៥៨ | ៣០.៥៨ |
| ប្រទេស | ចំនួនភាគហ៊ុន | បរិវិសកម្ម (លាន SDR) |
| ឥណ្ឌូណេស៊ី | ១.០៤៩ | ១០.៤៩ |
| អ៊ីរ៉ង់-សាធារណរដ្ឋអ៊ិស្លាម | ១.៦៥៩ | ១៦.៥៩ |
| អ៊ីរ៉ាក់ | ៣៥០ | ៣.៥០ |
| អ៊ីស្រាអែល | ៤៧៤ | ៤.៧៤ |
| កូឌីវ័រ | ១៧៦ | ១.៧៦ |
| ហ្សាម៉ៃកា | ១៨១ | ១.៨១ |
| ហ្សកដង់ | ៩៧ | ០.៩៧ |
| កម្ពុជាប្រជាធិបតេយ្យ | ៩៣ | ០.៩៣ |
| កេនយ៉ា | ១៧២ | ១.៧២ |
| កូរ៉េ | ៤៤៩ | ៤.៤៩ |
| គូវ៉ែត | ៩៣០ | ៩.៣០ |
| ឡាវ-សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ | ៦០ | ០.៦០ |
| លីបង់ | ១៤២ | ១.៤២ |
| ឡេសូតូ | ៥០ | ០.៥០ |
| លីបេរីយ៉ា | ៨៤ | ០.៨៤ |
| លីប៊ីយ៉ានអារ៉ាប់ហ្សាម៉ាហ៊ីរីយ៉ា | ៥៤៩ | ៥.៤៩ |
| ម៉ាដាហ្គាស្កា | ១០០ | ១.០០ |
| ម៉ាឡាវី | ៧៧ | ០.៧៧ |
| ម៉ាឡេស៊ី | ៥៧៩ | ៥.៧៩ |
| ម៉ាឌីវ | ៥០ | ០.៥០ |
| ម៉ាលី | ៨១ | ០.៨១ |
| ម៉ាល់តា | ៧៥ | ០.៧៥ |
| ម៉ូរីតានី | ៦៣ | ០.៦៣ |
| ម៉ូរីស្យុស | ៨៧ | ០.៨៧ |
| ម៉ិកស៊ិក | ១.១៩២ | ១១.៩២ |
| ម៉ារ៉ុក | ៣៤៨ | ៣.៤៨ |

| | | |
|---|---|---|
| ម៉ូហ្សំប៊ិច | ៩៧ | 0.៩៧ |
| នេប៉ាល់ | ៦៩ | 0.៦៩ |
| ប្រទេស | ចំនួនភាគហ៊ុន | បរិវិសកម្ម (លាន SDR ) |
| នីការ៉ាហ្គា | ១០២ | ១.០២ |
| នីហ្សេ | ៦២ | 0.៦២ |
| ~~នៃហ្សេរី~~ | ~~៨៤៤~~ | ~~៨.៤៤~~ |
| អូម៉ង់ | ៩៤ | 0.៩៤ |
| ប៉ាគីស្ថាន | ៦៦០ | ៦.៦០ |
| ប៉ាណាម៉ា | ១៣១ | ១.៣១ |
| ~~ប៉ាពួញូវែលហ្គីណេ~~ | ~~៩៦~~ | ~~0.៩៦~~ |
| ប៉ារ៉ាហ្គាយ | ៨០ | 0.៨០ |
| ប៉េរូ | ៣៧៣ | ៣.៧៣ |
| ហ្វីលីពីន | ៤៤៤ | ៤.៤៤ |
| ព័រទុយហ្គាល | ៣៨២ | ៣.៨២ |
| កាតារ់ | ១៣៧ | ១.៣៧ |
| រូម៉ានី | ៥៥៥ | ៥.៥៥ |
| រ៉ាន់ដា | ៧៥ | 0.៧៥ |
| សាំងគ្រីស្តហ្វ័រ និងណេវីស | ៥០ | 0.៥០ |
| សាំងលូស៊ា | ៥០ | 0.៥០ |
| សាំងវ៉ាំងសង់ | ៥០ | 0.៥០ |
| សៅតូម និង ប្រាំងស៊ីប | ៥០ | 0.៥០ |
| អារ៉ាប៊ីសាអូឌីត | ៣.១៣៧ | ៣១.៣៧ |
| សេនេហ្គាល | ១៤៧ | ១.៤៧ |
| ស៊ីសែល | ៥០ | 0.៥០ |
| សៀរ៉ាលេអូន | ៧៥ | 0.៧៥ |
| សាំងហ្គាពួរ | ១៥៤ | ១.៥៤ |
| សូឡូម៉ុង អ៊ីស្លង់ | ៥០ | 0.៥០ |
| សូម៉ាលី | ៧៨ | 0.៧៨ |
| អេស្ប៉ាញ | ១.២៨៥ | ១២.៨៥ |

-47-

| | | |
|---|---|---|
| ស្រីលង្កា | ២៧១ | ២.៧១ |
| ស្វីដង់ | ២០៦ | ២.០៦ |
| ប្រទេស | ចំនួនភាគហ៊ុន | បរិវិសកម្ម (លាន SDR) |
| ស៊ីរណាំ | ៩២ | ០.៩២ |
| ស៊ីរសាធារណៈរដ្ឋអារ៉ាប់ | ១៦៨ | ១.៦៨ |
| ស្វស៊ីឡែន | ៥៨ | ០.៥៨ |
| តង់សានី | ១៤១ | ១.៤១ |
| ថៃឡង់ដ៍ | ៤២១ | ៤.២១ |
| តូហ្គោ | ៧៧ | ០.៧៧ |
| ទ្រីនីដា និងតូបាហ្គូ | ២០៣ | ២.០៣ |
| ទុយនីស៊ី | ៥៦ | ១.៥៦ |
| ទួរគី | ៤៦២ | ៤.៦២ |
| អារ៉ាប់រួម | ៣៧២ | ៣.៧២ |
| អ៊ូហ្គង់ដា | ១៣២ | ១.៣២ |
| អ៊ូរូហ្គាយ | ២០២ | ២.០២ |
| វ៉ាណាទូ | ៥០ | ០.៥០ |
| វេណេហ្ស៊ុយអេឡា | ១.៤២៧ | ១៤.២៧ |
| វៀតណាម | ២២០ | ២.២០ |
| សាម៉ោវខាងលិច | ៥០ | ០.៥០ |
| យេម៉ែន សាធារណៈរដ្ឋ អារ៉ាប់ | ៦៧ | ០.៦៧ |
| យេម៉ែនសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យ | ១១៥ | ១.១៥ |
| យូហ្គោស្លាវី | ៦៣៥ | ៦.៣៥ |
| ហ្សាអៀរ | ៣៣៨ | ៣.៣៨ |
| ហ្សំប៊ី | ៣១៨ | ៣.១៨ |
| ហ្ស៊ីមបាវេ | ២៣៦ | ២.៣៦ |
| | ៤០.៥២៧ | ៤០៥.២៧ |
| សរុប | ១០០,០០០ | ១.០០០,០០ |

## តារាង ខ

## ការបោះឆ្នោតជ្រើសរើសនាយក ( Election of Directors )

១- បេក្ខជនសំរាប់តំណែងនាយក នឹងត្រូវបានជ្រើសតាំងដោយអភិបាលដោយកំណត់ថា អភិបាលម្នាក់អាចជ្រើសតាំងបានតែបុគ្គលម្នាក់ ។

២- ការបោះឆ្នោតជ្រើសរើសនាយក នឹងត្រូវធ្វើដោយការបោះឆ្នោតរបស់អភិបាល ។

៣- ក្នុងការបោះឆ្នោតរើសនាយក អភិបាលម្នាក់ៗ នឹងបោះឆ្នោតឱ្យសំរាប់តែបេក្ខជនម្នាក់ នូវសំលេងទាំងអស់របស់សមាជិកដែលខ្លួនតំណាងឱ្យ តាមផ្នែក (ក) នៃមាត្រា ៤០ ។

៤- មួយភាគបួននៃចំនួននាយក នឹងត្រូវជ្រើសរើសដោយឡែក ពីម្នាក់ដោយអភិបាល នៃសមាជិកនីមួយ ៗ ដែលមានចំនួនភាគហ៊ុនច្រើនជាងគេ ។ប្រសិនបើចំនួននាយកមិនអាចចែកដាច់នឹងបួន ចំនួននាយកដែលបានជ្រើសរើសនឹងទៅជាមួយភាគបួននៃចំនួនតិចបន្ទាប់ ដែលអាចចែកដាច់នឹងបួន ។

៥- នាយកដែលនៅសល់នឹងត្រូវជ្រើសរើសដោយអភិបាលផ្សេងទៀតស្របទៅកំណត់នៃកថាខ័ណ្ឌ ៦ ដល់ ១១ នៃតារាងនេះ ។

៦- ប្រសិនបើចំនួននៃបេក្ខជនដែលជ្រើសតាំងស្មើនឹងចំនួននាយកដែលនៅសល់ដែលត្រូវជ្រើសរើសបេក្ខជនទាំងអស់ នឹងត្រូវបានជ្រើសរើសនៅក្នុងការបោះឆ្នោតលើកទីមួយលើកលែងតែបេក្ខជនម្នាក់ ឬច្រើននាក់ដែលបានទទួលសំឡេងតិចជាងភាគរយអប្បបរិមា នៃសំឡេងសរុបដែលកំណត់ដោយក្រុមប្រឹក្សា សំរាប់ការបោះឆ្នោតជ្រើសរើសនេះ នឹងមិនត្រូវបានជ្រើសរើស ប្រសិនបើបេក្ខជនណាម្នាក់នឹងបានទទួលសំឡេងច្រើនជាងភាគរយអតិបរិមា នៃសំឡេងសរុប ដែលកំណត់ដោយក្រុមប្រឹក្សា ។

៧-ប្រសិនបើចំនួនបេក្ខជនដែលបានជ្រើសតាំងលើសពីចំនួននាយកនៅសល់ដែលត្រូវជ្រើសរើស បេក្ខជនទាំងឡាយណាដែលបានទទួលសំឡេងច្រើនជាងគេបំផុត នឹងត្រូវបានជ្រើសរើស លើកលែងតែបេក្ខជនណាដែលទទួលសំឡេងតិចជាងភាគរយអប្បបរមា នៃសំឡេងសរុបដែលកំណត់ដោយក្រុមប្រឹក្សា ។

៨-ប្រសិនបើចំនួននាយកដែលនៅសល់មិនអាចជ្រើសរើសបាននៅក្នុងការបោះឆ្នោត

លើកទីមួយទេ នឹងត្រូវធ្វើការបោះឆ្នោតលើកទីពីរ ។ បេក្ខជនម្នាក់ ឬបេក្ខជនទាំងឡាយដែលមិនបានជ្រើសរើសក្នុងការបោះឆ្នោតលើកទីមួយ អាចជ្រើសតាំងជាថ្មីសំរាប់ការជ្រើសរើស ។

៩- ក្នុងការបោះឆ្នោតលើកទីពីរ ការបោះឆ្នោតនឹងត្រូវកំរិតត្រឹមតែ(១)អភិបាលទាំងឡាយណាដែលបានបោះឆ្នោតលើកទីមួយសំរាប់បេក្ខជនដែលមិនបានជាប់ឆ្នោត និង (២) អភិបាលទាំងឡាយណា ដែលបានបោះឆ្នោតលើកទីមួយ សំរាប់បេក្ខជនជាប់ឆ្នោតម្នាក់ដែលបានទទួលភាគរយផតិបរិមានៃសំឡេងសរុប កំណត់ដោយក្រុមប្រឹក្សាមុនពេលលើកយកសំឡេងរបស់ខ្លួនមកពិចារណា ។

១០-ក្នុងការកំណត់ថាពេលណាបេក្ខជនជាប់ឆ្នោតម្នាក់បានទទួលសំឡេងច្រើនជាងភាគរយអតិបរិមាសំឡេងឆ្នោតរបស់អភិបាល ដែលបានឆ្នោតចំនួនច្រើនបំផុតនៃសំឡេងសំរាប់បេក្ខជននោះនឹងត្រូវបានរាប់មុនគេ បន្ទាប់មកសំឡេងរបស់អភិបាល ដែលបោះឆ្នោតចំនួនច្រើន បន្ទាប់នឹងជាបន្តបន្ទាប់រហូតដល់ភាគរយសនេះ ។

១១-ប្រសិនបើចំនួននាយកដែលនៅសល់ទាំងអស់ មិនត្រូវបានជ្រើសរើសបន្ទាប់ពីការបោះឆ្នោតលើកទីពីរ ការបោះឆ្នោតជាបន្តទៀតនឹងត្រូវធ្វើឡើងតាមគោល ការណ៍ដូចគ្នា រហូតដល់ចំនួននាយកដែលនៅសល់ត្រូវបានជ្រើសរើស នៅពេលដែលនៅសល់តែនាយកម្នាក់ត្រូវជ្រើសរើស នាយកនេះត្រូវជ្រើសរើសដោយភាគច្រើនសាមញ្ញ នៃសំឡេងដែលនៅសល់ ហើយនឹងត្រូវចាត់ទុកថាត្រូវបានជ្រើសរើសដោយសំឡេងទាំងអស់នោះ ។